## ជំពូកទី ៨

# សុខភាពផ្លូវភេទ

## ការទប់ស្កាត់ជំងឺកាមរោគ រួមទាំងវីរុសហ៊ីវ/អេដស៍




សុខភាពខាងផ្លូវភេទ គឺជាស្ថានភាពផ្លូវកាយនិងផ្លូវអារម្មណ៏នៃសុខុមាលភាពដែលអនុញ្ញាតឱ្យយើងសប្បាយរីករាយ និងសំដែងអារម្មណ៏នៃផ្លូវភេទ ។ យើងអាចរក្សាសុខភាពផ្លូវភេទរបស់យើងឱ្យមាំមួន ដោយការរៀនអំពីរាងកាយរបស់យើង និងអ្វីដែលផ្តល់ការរំភើបរីករាយដល់យើង រួមទាំងការកាត់បន្ថយអ្វីដែលងាយរងគ្រោះនៃការមិនចង់មានផ្ទៃពោះ និងកុំឱ្យឆ្លងជំងឺកាមរោគតាមរយៈការរួមភេទ ។

នៅតាមសហគមន៏ជាច្រើនតែងមានជំនឿខុសទំនង ដែលអាចបង្កជាទុក្ខទោសអំពីអ្វីទៅជាស្ត្រីត្រឹមត្រូវ ឬ ស្ត្រីគ្រប់ល័ក្ខ ជំនឿទាំងនេះអាចមានការលំបាកសំរាប់ស្ត្រីក្នុងការមានរឿងរួមភេទប្រកបដោយផាសុកភាព ។ ដោយសារតែស្ត្រីមានអំណាចតិចតួចចំពោះការសំរេចចិត្តក្នុងរឿងរួមភេទ ហើយជារឿយៗមិនអាចប្រឆាំងចំពោះការរួមភេទ ស្ត្រីរាប់លាននាក់ជុំវិញពិភពលោកត្រូវបានឆ្លងវីរុសហ៊ីវនិងជំងឺកាមរោគផ្សេងៗ ។ ជួនកាលមនុស្សម្នាគិតថា ស្ត្រីម្នាក់ដែលមានពិការភាពមិនអាចឆ្លងជំងឺឡើយ ។ រឿងនេះមិនពិតឡើយ ។ ស្ត្រីពិការនិងស្ត្រីមិនពិការ អាចឆ្លងជំងឺកាមរោគដូចគ្នាអញ្ចឹងដែរ ។

តាមពិតក្មេងស្រីនិងស្ត្រីពិការ គឺស្ថិតក្នុងភាពងាយរងគ្រោះចំពោះជំងឺកាមរោគជាងស្ត្រីមិនពិការ ។ ពួកគេមិនត្រឹមតែមានការលំបាកក្នុងការទទួលបានព័ត៌មានអំពីសុខភាពខាងផ្លូវភេទប៉ុណ្ណឹងឡើយ ពួកគេប្រហែលមានការត្រួតត្រាតិចតួចលើរបៀប និងជាមួយបុគ្គលដែលខ្លួនរួមរ័ក្ស ។ ករណីនេះកាន់តែធ្វើឱ្យពួកគេងាយរងគ្រោះចំពោះការកេងយកចំណេញក្នុងរឿងរួមភេទ ហើយកាន់តែងាយរងគ្រោះនៃការឆ្លងជំងឺកាមរោគ រួមទាំងវីរុសហ៊ីវទៀតផង ។ ចំពោះព័ត៌មានបន្ថែមអំពីការរំលោភបំពានខាងផ្លូវភេទចំពោះស្ត្រីពិការ ចូរអានជំពូកទី 14 ។ នៅក្នុងជំពូកនេះមានព័ត៌មានអំពីវីរុសហ៊ីវ/អេដស៏ និងជំងឺកាមរោគផ្សេងៗ និងវិធីទប់ស្កាត់ជំងឺទាំងនោះ ។ ការមានព័ត៌មានត្រឹមត្រូវ ស្ត្រីអាចបោះជំហានទៅរកការការពារខ្លួនឯង និងរីករាយចំពោះការរួមភេទប្រកបដោយសផាសុកភាព ។

## តើអ្វីទៅជាជំងឺកាមរោគ? [Sexual Transmitted Diseases (STDs)]

ជំងឺកាមរោគ ជាជំងឺឆ្លងពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតនៅពេលរួមរ័ក្ស ។ ជំងឺកាមរោគអាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈប្រភេទរួមរ័ក្សណាមួយ ។ វាអាចជាការរួមរ័ក្សដោយលិង្គស៊កចូលរន្ធយោនី ឬ លិង្គស៊កចូលរន្ធគូទ ឬ ការរួមរ័ក្សដោយប្រើមាត់ ( មាត់នឹងលិង្គ ឬ មាត់នឹងយោនី) ។ ជួនកាលជំងឺកាមរោគអាចឆ្លងបានដោយគ្រាន់តែត្រដុសលិង្គដែលកើតជំងឺ ឬ យោនីដែលកើតជំងឺទៅនឹងប្រដាប់ភេទរបស់បុគ្គលម្នាក់ទៀត ។



## ជំងឺឆ្លងដែលមិនព្យាបាលគឺមានគ្រោះថ្នាក់

ជំងឺកាមរោគជាច្រើនអាចត្រូវបានព្យាបាលដោយថ្នាំពេទ្យ ។ បើជំងឺទាំងនោះមិនបានព្យាបាលឱ្យទាន់ពេលវេលា ជំងឺកាមរោគអាចបណ្តាលឱ្យគ្មានលទ្ធភាពផ្តល់កំណើតកូនទាំងចំពោះស្ត្រីនិងបុរស, ទារកអាចកើតមិនគ្រប់ខែ ឬ តូចពេក ឬ ពិការភ្នែក, មានផ្ទៃពោះក្នុងដៃស្បូន, ឈឺរាប់ខែក្នុងពោះផ្នែកខាងក្រោម, កើតជំងឺមហារីកទ្វារស្បូន, ឬ ស្លាប់ដោយសារជំងឺឆ្លងយ៉ាងធ្ងន់ធ្ងរ ។

## រោគសញ្ញានៃជំងឺកាមរោគ

អ្នកប្រហែលជាមានជំងឺកាមរោគ បើអ្នកមានរោគសញ្ញាមួយ ឬ ច្រើនដូចតទៅ :

- ធ្លាក់សពីរន្ធយោនីខុសធម្មតា ។
- ក្លិនខុសធម្មតាពីរន្ធយោនី ។
- ឈឺ ឬ មានអារម្មណ៍ខុសធម្មតាក្នុងពោះផ្នែកក្រោម ជាពិសេសពេលកំពុងរួមរ័ក្សជាមួយលិង្គស៊កចូលរន្ធយោនី ។
- រមាស់ខ្លាំង, កន្ទួលរមាស់, ដំបៅ, ឬ រលាក/ដំបៅត្រង់ប្រដាប់ភេទ ។

អាស្រ័យលើពិការភាពរបស់អ្នក វាប្រហែលជាពិបាកសំរាប់អ្នកក្នុងការដឹងថា តើអ្នកមានរោគសញ្ញាទាំងនេះឬយ៉ាងណា ។ អ្នកប្រហែលជាត្រូវការនិយាយប្រាប់នរណាម្នាក់ដែលអ្នកទុកចិត្ត ដើម្បីជួយអ្នកឱ្យចេះពិនិត្យរោគសញ្ញាទាំងឡាយនៃជំងឺកាមរោគ ។

**ធ្លាក់សមានការប្រែប្រួល (ជាតិរំអិលក្នុងយោនីមានការប្រែប្រួល)**

វាជារឿងធម្មតាក្នុងការមានជាតិសើម ឬ ជាតិរំអិល ( ធ្លាក់ស) ខ្លះៗក្នុងរន្ធយោនី ។ នេះជាវិធីតាមធម្មជាតិដែលយោនីលាងសំអាតនិងការពារខ្លួនវា ។ ជាតិរំអិលប្រែប្រួលនៅអំឡុងនៃវដ្តឈាមរដូវ ។ ជាតិរំអិលមានសភាពខាប់ជាងមុន, ថ្លានិងរអិលខ្លាំងចំនួនប្រមាណ 14ថ្ងៃ មុនពេលអ្នកចាប់មានឈាមរៀងរាល់ខែ ។ ការប្រែប្រួលផ្សេងទៀតនៅក្នុងជាតិរំអិល គឺចំនួន ឬ ក្លិនវាពីរន្ធយោនីរបស់អ្នក ជួនកាលមានន័យថាអ្នកមានជំងឺរលាក ប៉ុន្តែពិបាកដឹងណាស់ពីជាតិរំអិល ថាតើអ្នកមានជំងឺរលាកប្រភេទណា ។ ចំពោះព័ត៌មានអំពីករណីធ្លាក់ស ដែលមិនមែនជាជំងឺកាមរោគ ( ផ្សិត**ឃីស**និងជំពូកបាក់តេរីនៃរន្ធយោនី) ចូរអានពីទំព័រ 111 ដល់ 113 ។

### វិធីពិនិត្យរកមើលរោគសញ្ញានៃជំងឺកាមរោគ

**បើអ្នកជាស្ត្រីពិការភ្នែក :-** ពេលលាងសំអាតប្រដាប់ភេទរបស់អ្នក ចូរប្រើម្រាមដៃដើម្បីស្ទាបពិនិត្យជាតិរំអិល/ធ្លាក់ស, ដុំពក ឬ កន្លែងដែលប៉ះទៅមានការឈឺចាប់ខុសពីធម្មតា ។ ចូរធ្វើបែបនេះមួយសប្តាហ៍ម្តង ។ បើអ្នកធ្វើបែបនេះរាល់ថ្ងៃ វានឹងពិបាកសំរាប់អ្នកក្នុងការសំគាល់អ្វីៗដែលប្រែប្រួល ។



**បើប្រអប់ដៃរបស់អ្នកមិនសូវមាន ឬ គ្មានលទ្ធភាពស្ទាបពិនិត្យ :** បើអ្នកមិនអាចប្រើម្រាមដៃស្ទាបពិនិត្យប្រដាប់ភេទសំរាប់រកមើលអ្វីៗដែលប្រែប្រួល ចូរសាកល្បងប្រើកញ្ចក់ពិនិត្យមើលវាជំនួសវិញ ។ បើអ្នកមិនអាចកាន់កញ្ចក់បាន ចូរដាក់វាផ្ទាល់នឹងកម្រាលផ្ទះ ហើយចោងហោងពីលើកញ្ចក់នោះដើម្បីពិនិត្យមើល ។

**បើអ្នកមានរបួសសរសៃប្រសាទឆ្អឹងខ្នង :** បើអ្នកអាចស្ទាបពិនិត្យនិងមើលប្រដាប់ភេទបាន ចូរធ្វើបែបនេះមួយសប្តាហ៍ម្តង នៅពេលអ្នកកំពុងងូតទឹក ។ បើអ្នកមិនអាចធ្វើបែបនេះបានដោយខ្លួនឯង ចូរស្នើសុំឱ្យនរណាម្នាក់ដែលអ្នកទុកចិត្តឱ្យគេជួយអ្នក ។ អ្នកប្រហែលជាមិនដឹងឡើយ បើមានអ្វីមួយឈឺក្នុងពោះផ្នែកខាងក្រោម ឬ រមាស់ក្នុងប្រដាប់ភេទ ។ ប៉ុន្តែបើអ្នកមានជំងឺកាមរោគអ្វីមួយ ហើយមិនបានព្យាបាលទាន់ពេលវេលា អ្នកអាចកើតជំងឺសម្ពាធឈាមលើសស្រួចស្រាវ ។ នេះជារឿងដ៏គ្រោះថ្នាក់ខ្លាំងណាស់ ។ ចូរអានពីទំព័រ 117 ដល់ 119 សំរាប់វិធីព្យាបាល ។



**បើអ្នកមិនសូវមាន ឬ គ្មានចលនាក្នុងជើងរបស់អ្នក :** បើអាចធ្វើកើត ចូរស្វែងរកស្ថានភាពដែលអ្នកអាចស្ទាបពិនិត្យប្រដាប់ភេទជាមួយម្រាមដៃ ពេលអ្នកកំពុងលាងសំអាតវា ឬ ប្រើកញ្ចក់ដើម្បីពិនិត្យមើលវា ។ បើចាំបាច់ ចូរស្នើសុំឱ្យនរណាម្នាក់ដែលអ្នកទុកចិត្តឱ្យគេជួយទប់ជើងរបស់អ្នកឱ្យជាប់ ។

## រោគទ្រីកូម៉ូណាស់ [trichomonas]

**ទ្រីកូម៉ូណាស់** គឺជាជំងឺកាមរោគម្យ៉ាងដែលរមាស់និងពិបាកទ្រាំបំផុត ។ តាមធម្មតា វាគ្មានបង្ហាញរោគសញ្ញាលើបុរសឡើយ ប៉ុន្តែលិង្គរបស់បុរសដែលផ្ទុកជំងឺនេះ អាចចម្លងទៅឱ្យស្ត្រីនៅអំឡុងពេលរួមរ័ក្ស ។

### រោគសញ្ញា

- ធ្លាក់សមានពណ៌ប្រផេះ ឬ លឿង, សភាពជាពពុះដុំៗ ។
- ធ្លាក់សមានក្លិនស្អុយ ។
- ម្ដុំប្រដាប់ភេទនិងរន្ធយោនីមានពណ៌ក្រហមនិងរមាស់ ។
- ឈឺផ្សារ ឬ ក្រហាយនៅពេលអ្នកជុះនោម ។

បើអ្នកគ្មានលទ្ធភាពទៅធ្វើតេស្តដើម្បីដឹងឱ្យច្បាស់ថា អ្នកកើតរោគ**ទ្រីកូម៉ូណាស់** ចូរលេបថ្នាំពេទ្យមួយមុខក្នុងចំណោមថ្នាំពេទ្យទាំងឡាយដែលមានរាយឈ្មោះដូចខាងក្រោម ។ បើអ្នកមិនអាចទៅធ្វើតេស្ត វាជាការប្រសើរបំផុតក្នុងការលេបថ្នាំពេទ្យដែលមានរាយឈ្មោះនៅទំព័រ 162 ពីព្រោះជំងឺឆ្លងអាចបានបង្កពីជំងឺកាមរោគផ្សេងទៀត ។

| ថ្នាំពេទ្យសំរាប់ព្យាបាលកាមរោគទ្រីកូម៉ូណាស់ (trichomonas) | | |
|---|---|---|
| ថ្នាំពេទ្យ | លេបចំនួនប៉ុន្មាន មីលីក្រាម ឬ ក្រាម? | លេបពេលណា? ប៉ុន្មានដង និង ប៉ុន្មានថ្ងៃ? |
| ថ្នាំ **មេត្រូនីដាហ្សុល** = metronidazole | 400 ទៅ 500 មីលីក្រាម (mg) | លេប 2 ដង ក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ។ |
| **ឬ**ថ្នាំ **មេត្រូនីដាហ្សុល** = metronidazole | 2 ក្រាម (grams) = (2000 mg) | លេបតែម្តងគត់។ |
| (ហាមលេបថ្នាំ **មេត្រូនីដាហ្សុល** នៅអំឡុងពេល 3 ខែដំបូងនៃការមានផ្ទៃពោះ) | | |
| **ឬ**ថ្នាំ **ក្លាំងដាមីស៊ីន** = clindamycin | 300 មីលីក្រាម (mg) | លេប 2 ដង ក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ។ |
| **សំខាន់ :** ហាមផឹកគ្រឿងស្រវឹងគ្រប់យ៉ាងនៅអំឡុងពេលផឹកថ្នាំ **មេត្រូនីដាហ្សុល**។ ព័ត៌មានបន្ថែមអំពី **មេត្រូនីដាហ្សុល**, ចូរអានទំព័រ 347។ ដៃគូ/ប្តីរបស់អ្នកក៏ត្រូវការព្យាបាលដោយការផឹកថ្នាំប្រភេទនេះដូចគ្នាដែរ។ | | |

## រោគប្រមេះទឹកបាយល្អក់ [gonorrhea] និង រោគប្រមេះទឹកបាយថ្លា [chlamydia]

ជំងឺកាមរោគ**ប្រមេះទឹកបាយល្អក់** និង **ប្រមេះទឹកបាយថ្លា** គឺជាជំងឺឆ្លងកាចសាហាវ។ រោគទាំងពីរនេះងាយជាសះស្បើយ បើវាត្រូវបានព្យាបាលទាន់ពេល។ បើរោគទាំងពីរនេះមិនបានព្យាបាល វាក្លាយទៅជាជំងឺធ្ងន់ធ្ងរ និងធ្វើឱ្យទាំងបុរស និងស្ត្រីគ្មានលទ្ធភាពផ្តល់កំណើតកូន។ ចំពោះបុរស រោគសញ្ញានឹងបង្ហាញឡើងក្នុងរវាងពី 2 ទៅ 5 ថ្ងៃ បន្ទាប់ពីបានរួមភេទជាមួយបុគ្គលដែលផ្ទុកមេរោគ។ ចំពោះស្ត្រីវិញ រោគសញ្ញាប្រហែលជាមិនបង្ហាញអាចរាប់អាទិត្យ ឬ រាប់ខែ។ ប៉ុន្តែទាំងស្ត្រីនិងបុរសអាចផ្ទុកកាមរោគទាំងនេះ ដោយគ្មានបង្ហាញរោគសញ្ញាអ្វីទាំងអស់។ ទោះបីបុគ្គលម្នាក់គ្មានបង្ហាញរោគសញ្ញាក៏ដោយ បុគ្គលនោះនៅតែអាចចម្លងកាមរោគទាំងពីរនេះទៅឱ្យបុគ្គលម្នាក់ផ្សេងទៀត។



រោគសញ្ញាទូទៅតែងបង្ហាញចំពោះស្ត្រី គឺ :-

- ធ្លាក់សមានពណ៌លឿង ឬ បៃតង ពីរន្ធយោនី ឬ រន្ធគូទ។
- ឈឺផ្សារ ឬ ក្រហាយពេលអ្នកជុះនោម។
- គ្រុនក្តៅ។
- ឈឺចុកក្នុងពោះផ្នែកក្រោម។
- ឈឺចុក ឬ ចេញឈាមនៅពេលកំពុងរួមភេទ។
- គ្មានរោគសញ្ញាអ្វីទាំងអស់។



រោគសញ្ញាទូទៅតែងបង្ហាញចំពោះបុរស គឺ :-

- ធ្លាក់សចេញពីលិង្គ។
- ឈឺផ្សារ ឬ ក្រហាយពេលអ្នកជុះនោម។
- ឈឺផ្សារ ឬ ហើមពងស្វាស។
- គ្មានរោគសញ្ញាអ្វីទាំងអស់។

**ការព្យាបាល :** បើអ្នកមានរោគសញ្ញាណាមួយចំពោះរោគ**ប្រមេះទឹកបាយល្អក់** ឬ រោគ**ប្រមេះទឹកបាយថ្លា** ហើយអ្នកបានរួមភេទដោយគ្មានប្រើស្រោមអនាម័យជាមួយបុគ្គលម្នាក់ អ្នកគិតថាខ្លួនឯងប្រហែលជាបានឆ្លងរោគណាមួយ ចូរព្យាយាមទៅធ្វើតេស្តដើម្បីឱ្យដឹងថាអ្នកឆ្លងជំងឺមួយណា ដូច្នេះអ្នកនឹងដឹងច្បាស់ថាត្រូវលេបថ្នាំពេទ្យប្រភេទណាមួយដើម្បីព្យាបាលរោគនៅឱ្យជាដាច់។

| **ថ្នាំពេទ្យសំរាប់ព្យាបាលរោគប្រមេះទឹកបាយល្អក់** (gonorrhea) | | |
|---|---|---|
| ថ្នាំពេទ្យ | លេបចំនួនប៉ុន្មាន មីលីក្រាម ឬ ក្រាម? | លេបពេលណា? ប៉ុន្មានដង និង ប៉ុន្មានថ្ងៃ? |
| ថ្នាំ **សេហ្វិចស៊ីម** = cefixime | 400 មីលីក្រាម (mg) | លេបទាំងអស់ តែម្តងគត់។ |
| **ឬ** ថ្នាំ **ស៊ីប្រូផ្លូសាកស៊ីន** = ciprofloxacin | 500 មីលីក្រាម (mg) | លេបទាំងអស់ តែម្តងដងគត់។ |

| **ថ្នាំពេទ្យសំរាប់ព្យាបាលរោគប្រមេះទឹកបាយថ្លា** (chlamydia) | | |
|---|---|---|
| ថ្នាំពេទ្យ | លេបចំនួនប៉ុន្មាន មីលីក្រាម ឬ ក្រាម? | លេបពេលណា? ប៉ុន្មានដង និង ប៉ុន្មានថ្ងៃ? |
| ថ្នាំ **អាហ្ស៊ីត្រូម៉ីស៊ីន** = azithromycin | 1 ក្រាម (g) | លេបទាំងអស់ តែម្តងគត់។ |
| **ឬ** ថ្នាំ **ដុកស៊ីស៊ីគ្លីន** = doxycycline | 100 មីលីក្រាម (mg) | លេប 2 ដង ក្នុងមួយថ្ងៃ សំរាប់ 7ថ្ងៃ។ |
| **ឬ** ថ្នាំ **ដុកស៊ីស៊ីគ្លីន** = tetracycline | 500 មីលីក្រាម (mg) | លេប 4 ដង ក្នុងមួយថ្ងៃ សំរាប់ 7ថ្ងៃ។ |
| **ឬ** ថ្នាំ **អេរ៊ីត្រូម៉ីស៊ីន** = erythromycin | 500 មីលីក្រាម (mg) | លេប 4 ដង ក្នុងមួយថ្ងៃ សំរាប់ 7ថ្ងៃ។ |

គួរឱ្យស្តាយការធ្វើតេស្តតែងមិនងាយរកបានជានិច្ចឡើយ ដូច្នេះវាជាការប្រសើរបំផុតដែលអ្នកជំងឺត្រូវលេបថ្នាំពេទ្យ សំរាប់ជំងឺឆ្លងច្រើនប្រភេទ។ បុគ្គលម្នាក់អាចកើតជំងឺឆ្លងចម្រុះគ្នាក្នុងពេលតែមួយ មូលហេតុបានបង្កឡើងមិនត្រឹមតែរោគ**ប្រមេះទឹកបាយល្អក់**និង**ប្រមេះទឹកបាយថ្លា**ប៉ុណ្ណឹងឡើយ ប៉ុន្តែវាបានបង្កដោយកាមរោគ**ទ្រីកូម៉ូណាស៍**ផងដែរ (ចូរអានទំព័រ 159) និងបាក់តេរីនៃយោនី (ចូរអានទំព័រ 113)។ ថ្នាំពេទ្យសំរាប់ព្យាបាលជំងឺឆ្លងទាំងអស់នេះមានចុះឈ្មោះនៅក្នុងតារាងនៅទំព័រ 162។

## ជំងឺរលាកអាងត្រគាក (រលាកក្នុងស្បូន) [pelvic inflammatory disease (PID)]

ជំងឺរលាកអាងត្រគាក គឺជាឈ្មោះជំងឺឆ្លងណាមួយនៃផ្នែកប្រដាប់បន្តពូជស្ត្រីក្នុងពោះផ្នែកក្រោម។ ជារឿយៗ វាត្រូវបានហៅថា "ជំងឺរលាកក្នុងស្បូន"។ ជំងឺរលាកក្នុងស្បូនអាចកើតមកពីជំងឺកាមរោគមួយដែលមិនជាដាច់ស្រឡះ ជាពិសេសរោគ**ប្រមេះទឹកបាយល្អក់** ឬ **ប្រមេះទឹកបាយថ្លា**។

អ្នកប្រហែលជាមានរោគសញ្ញាមួយ ឬ ច្រើនមុខក្នុងចំណោមរោគសញ្ញាទាំងនេះ :-

- ឈឺចុកក្នុងពោះផ្នែកក្រោម។
- គ្រុនក្តៅខ្លាំង។
- អ្នកមានអាការៈមិនស្រួលខ្លួន និង ខ្សោយកំលាំង។
- ធ្លាក់សធុំក្លិនអាក្រក់ដែលមានពណ៌លឿង ឬ បៃតងពីរន្ធយោនី។
- ឈឺចាប់ ឬ ចេញឈាមពីរន្ធយោនីនៅពេលកំពុងរួមរ័ក្ស។



### ការព្យាបាល

ដោយសារតែជំងឺនេះជាទូទៅបង្កមូលហេតុពីមេរោគចំរុះ ថ្នាំច្រើនមុខត្រូវតែប្រើដើម្បីព្យាបាលវាឱ្យជាដាច់។ ចូរលេបថ្នាំដែលមានចុះឈ្មោះក្នុងតារាងនៅទំព័រ 162។

## ថ្នាំសំរាប់ព្យាបាលជំងឺកាមរោគប្រមេះទឹកបាយល្អក់, ប្រមេះទឹកបាយថ្លា, ទ្រីកូម៉ូណាស៍, បាក់តេរីនៃរយោនី និងជំងឺរលាកក្នុងស្បូន

បើអ្នកមានរោគសញ្ញានៃជំងឺឆ្លងទាំងនេះ ហើយអ្នកមិនអាចទៅធ្វើតេស្តដើម្បីដឹងឱ្យច្បាស់ថាតើជំងឺមួយណាដែលអ្នកបានឆ្លង ឬ ជំងឺឆ្លងនោះឈ្មោះអ្វី ចូរប្រើថ្នាំទាំងនេះចម្រុះគ្នា។

| ថ្នាំពេទ្យ | លេបចំនួនប៉ុន្មាន មីលីក្រាម ឬ ក្រាម? | លេបពេលណា? ប៉ុន្មានដង និង ប៉ុន្មានថ្ងៃ? |
|---|---|---|
| ថ្នាំ **សេហ្វិចស៊ីម =** cefixime | 400 មីលីក្រាម (mg) | លេបតែម្តងគត់។ |
| **ឬ** ថ្នាំ **ស៊ីប្រូផ្លូសាកស៊ីន =** ciprofloxacin | 500 មីលីក្រាម (mg) | លេបតែម្តងគត់។ |
| (ហាមប្រើថ្នាំ **ស៊ីប្រូផ្លូសាកស៊ីន** បើអ្នកមានផ្ទៃពោះ ឬ បំបៅដោះកូន)។ | | |
| **និង** | | |
| ថ្នាំ **អាហ្ស៊ីត្រូម៉ីស៊ីន** = azithromycin | 1 ក្រាម (gram) = 1000 មីលីក្រាម (mg) | លេបតែម្តងគត់។ |
| **ឬ** ថ្នាំ **អេរីត្រូម៉ីស៊ីន** = erythromycin | 500 មីលីក្រាម (mg) | លេប 4 ដងក្នុងមួយថ្ងៃ សំរាប់ 7ថ្ងៃ។ |
| **ឬ** ថ្នាំ **អាម៉ុកស៊ីស៊ីលីន** = amoxycillin | 500 មីលីក្រាម (mg) | លេប 3 ដងក្នុងមួយថ្ងៃ សំរាប់ 7ថ្ងៃ។ |
| **ឬ** ថ្នាំ **ដុកស៊ីស៊ីគ្លីន** = doxycycline | 100 មីលីក្រាម (mg) | លេប 4 ដងក្នុងមួយថ្ងៃ សំរាប់ 7ថ្ងៃ។ |
| (ហាមប្រើថ្នាំ **ដុកស៊ីស៊ីគ្លីន** បើអ្នកមានផ្ទៃពោះ ឬ បំបៅដោះកូន)។ | | |
| **និង** | | |
| **ឬ** ថ្នាំ **តេត្រាស៊ីគ្លីន** = tetracycline | 500 មីលីក្រាម (mg) | លេប 4 ដងក្នុងមួយថ្ងៃ សំរាប់ 7ថ្ងៃ។ |
| (ហាមប្រើថ្នាំ tetracycline បើអ្នកមានផ្ទៃពោះ ឬ បំបៅដោះកូន)។ | | |
| ថ្នាំ **មេត្រូនីដាហ្សុល** = metronidazole | 400 ទៅ 500 មីលីក្រាម (mg) | លេប 2 ដងក្នុងមួយថ្ងៃ សំរាប់7ថ្ងៃ។ |
| | **ឬ** 2 ក្រាម (grams)= 2000 មីលីក្រាម | លេបតែម្តងគត់។ |
| (ចៀសវាងប្រើថ្នាំ**មេត្រូនីដាហ្សុល** បើអ្នកមានផ្ទៃពោះ 3 ខែដំបូង។ ចូរប្រើថ្នាំ **ក្លាំងដាម៉ីស៊ីន** និង **ទីនីដាហ្សុល** ទាំងពីរមុខនេះជំនួសវិញ)។ | | |
| **ឬ** | | |
| ថ្នាំ **ក្លាំងដាម៉ីស៊ីន** = clindamycin | 300 មីលីក្រាម (mg) | លេប 2 ដងក្នុងមួយថ្ងៃ សំរាប់ 7ថ្ងៃ។ |
| | **ឬ** 5 ក្រាមនៃជាតិថ្នាំប៉ូម៉ាត 2% (ពេញ 1 ស៊ីរាំងដែលភ្ជាប់មកជាមួយប៉ូម៉ាត) | ដាក់ចូលរន្ធយោនី ពេលចូលដេកយប់ រៀងរាល់យប់ សំរាប់ 7ថ្ងៃ។ |
| **និង**ថ្នាំ **ទីនីដាហ្សុល =** tinidazole | 2 ក្រាម (grams) = 2000 មីលីក្រាម | លេបតែម្តងគត់។ |
| | **ឬ** 500 មីលីក្រាម (mg) | លេប 2 ដងក្នុងមួយថ្ងៃ សំរាប់ 5 ថ្ងៃ។ |

**សំខាន់ :** ហាមផឹកជាតិស្រវឹងគ្រប់យ៉ាងនៅអំឡុងពេលផឹកថ្នាំ **មេត្រូនីដាហ្សុល** ឬ ថ្នាំ **ទីនីដាហ្សុល**។ ដៃគូ/ប្តីរបស់អ្នកក៏ត្រូវការព្យាបាលដោយការផឹកថ្នាំប្រភេទនេះដូចគ្នាដែរ។

## ដំបៅលើប្រដាប់ភេទ [genital ulcers]

ដំបៅស្ទើរតែទាំងអស់ដែលកើតនៅលើប្រដាប់ភេទ គឺជាជំងឺកាមរោគ ប៉ុន្តែដំបៅគ្រែ, បូស ឬ របួសនានា ក៏អាចក្លាយជាដំបៅលើប្រដាប់ភេទដែរ ។ ដំបៅលើប្រដាប់ភេទណាមួយក៏ដោយ គួរត្រូវថែទាំដោយលាងសំអាតវាជាមួយសាប៊ូនិងទឹកស្អាត ។ ជូតផ្ងិតវាឱ្យស្ងួតដោយប្រយ័ត្ន ។ កំណាត់ ឬ កន្ទបដែលអ្នកប្រើសំរាប់ជូតសំអាតដំបៅ ចូរបោកគក់វាឱ្យស្អាតមុនពេលសមាជិកផ្សេងទៀតយកវាទៅប្រើម្តងទៀត ។ បើអាច អ្នកកើតជំងឺស្វាយគួរប្រើកន្សែង, កន្ទប និងវត្ថុលាងសំអាតដំបៅដាច់ដោយឡែកពីអ្នកគ្មានជំងឺ ។

**ចំណាំ** : កាលណាបុគ្គលម្នាក់កើតដំបៅលើប្រដាប់ភេទ វាជារឿងងាយក្នុងការឆ្លងជំងឺផ្សេងៗទៀតតាមរយៈដំបៅនេះ ជាពិសេសវីរុសហ៊ីវ និង ជំងឺថ្លើមប្រភេទ **បេ** ។ ដើម្បីទប់ស្កាត់ជំងឺឆ្លង ចូរចៀសវាងការរួមរក្សទាល់តែដំបៅនោះជាសះស្បើយ ។

## រោគស្វាយ [syphilis]

រោគស្វាយ គឺជាជំងឺកាមរោគកាចសាហាវដែលរាតត្បាតរាងកាយទាំងមូល ។ វាអាចកើតនៅក្នុងខ្លួនរាប់ឆ្នាំ ហើយកាន់តែដុនដាបឡើងៗជានិច្ច ។ រោគស្វាយអាចជាដាច់ស្រឡះ បើព្យាបាលវាទាន់ពេល ។

### រោគសញ្ញា



1. រោគសញ្ញាដំបូង គឺកើតដំបៅតូចមួយមិនឈឺអ្វីឡើយ ហើយមើលទៅដូចកើតមុន, ពងបែក, ឬសរាបតែសើម ឬ ដំបៅបើកមុខ ។ ដំបៅនេះកើតប្រមាណតែពីរ-បីថ្ងៃ ឬ ពីរ-បីអាទិត្យប៉ុណ្ណោះ ហើយរាបបាត់វិញដោយខ្លួនវា ។ ប៉ុន្តែជំងឺនេះបន្តរាលដាលពាសពេញរាងកាយ ។




2. រាប់អាទិត្យ ឬ រាប់ខែក្រោយមក បុគ្គលកើតរោគស្វាយអាចកើតជំងឺរលាកបំពង់ក, ក្តៅស្រៀវស្រាញតិចតួច, ពងបែកក្នុងមាត់, ហើមសន្លាក់ឆ្អឹង ឬ កើតកន្ទួលរមាស់ ជាពិសេសលើបាតដៃនិងបាតជើង ។ អំឡុងពេលនេះ បុគ្គលកើតរោគស្វាយអាចចម្លងរោគដល់អ្នកឯទៀត ។
3. តាមធម្មតារោគសញ្ញាទាំងនេះនឹងក្រាបបាត់ទៅវិញឯកឯង ប៉ុន្តែជំងឺនេះនៅតែបន្តផ្ទុកក្នុងខ្លួន ។ បើគ្មានការព្យាបាល រោគស្វាយអាចបណ្តាលឱ្យកើតជំងឺបេះដូង, ស្វិតអវៈយវៈ, ខូចខួរក្បាល, និងស្លាប់ ។

**ការព្យាបាល** - សំរាប់ការព្យាបាលរោគស្វាយឱ្យជាដាច់ស្រឡះ ការព្យាបាលឱ្យចប់ចុងចប់ដើមគឺជារឿងសំខាន់ខ្លាំងណាស់

- **បើរោគសញ្ញាបង្ហាញឡើងមានរយៈពេលតិចជាងមួយឆ្នាំ** ត្រូវចាក់ថ្នាំ **បេនហ្សាទីន ប៉េនីស៊ីលីន** (benzathine penicillin) ចំនួនទាំងអស់ 2.4 **លានយូនីត** តែត្រូវរំលែកថ្នាំពាក់កណ្តាលចាក់ត្រគាកម្ខាង និងពាក់កណ្តាលទៀតចាក់ត្រគាកម្ខាងទៀត ។ បុគ្គលដែលប្រតិកម្មថ្នាំ **ប៉េនីស៊ីលីន** (penicillin) ចូរលេបថ្នាំ **តេត្រាស៊ីគ្លីន** ជំនួសវិញ គឺផឹកចំនួន 500 **មីលីក្រាម** 4 ដងក្នុងមួយថ្ងៃ សំរាប់ 15 ថ្ងៃ ។
- **បើរោគសញ្ញាបង្ហាញឡើងលើសពីមួយឆ្នាំ** ត្រូវចាក់ថ្នាំ **បេនហ្សាទីន ប៉េនីស៊ីលីន** ម្តងចំនួន 2.4 **លានយូនីត** ត្រូវរំលែកថ្នាំពាក់កណ្តាលចាក់ត្រគាកម្ខាង និងពាក់កណ្តាលទៀតចាក់ត្រគាកម្ខាងទៀត-ថ្នាំនេះត្រូវចាក់ 1 អាទិត្យម្តង សំរាប់ 3 អាទិត្យជាប់គ្នា ( ចំនួនថ្នាំសរុប 7.2 **លានយូនីត** ) ។ បើមានប្រតិកម្មថ្នាំ **ប៉េនីស៊ីលីន** ចូរលេបថ្នាំ **តេត្រាស៊ីគ្លីន** ជំនួសវិញ គឺផឹកចំនួន 500 **មីលីក្រាម** 4 ដងក្នុងមួយថ្ងៃ សំរាប់ 30 ថ្ងៃ ។

**កំណត់ចំណាំ** : ស្ត្រីមានផ្ទៃពោះ ឬ ដំបៅដោះកូន បើសិនជាគាត់ប្រតិកម្មនឹងថ្នាំ **ប៉េនីស៊ីលីន** គាត់អាចផឹកថ្នាំ **អេរីត្រូមីស៊ីន** ជំនួសវិញ ( ចូរអានទំព័រ 343 ) ។ ប្តី/ដៃគូរបស់គាត់ ក៏ត្រូវការការព្យាបាលឱ្យចប់ចុងចប់ដើមផងដែរ ។

**ការមានផ្ទៃពោះ និង រោគស្វាយ**

ស្ត្រីមានផ្ទៃពោះអាចចម្លងរោគស្វាយទៅឱ្យទារកដែលមិនទាន់កើត ដែលអាចបណ្តាលឱ្យទារកកើតមិនគ្រប់ខែ, ទារកអាចខូចរាងកាយ, ឬ ទារកអាចស្លាប់។ អ្នកអាចទប់ស្កាត់បញ្ហានេះដោយការទៅធ្វើតេស្តឈាម និងធ្វើការព្យាបាលនៅពេលកំពុងមានផ្ទៃពោះ។ បើអ្នកនិងប្តី/ដៃគូរបស់អ្នកបានធ្វើតេស្តឈាម ហើយបង្ហាញថាអ្នកកើតរោគស្វាយពិតមែននោះ អ្នកនិងប្តី/ដៃគូរបស់អ្នកត្រូវតែព្យាបាលជាមួយថ្នាំពេទ្យគឺចាក់ចូលសាច់ដុំ មួយអាទិត្យម្តងៗ សំរាប់ 3 អាទិត្យជាប់គ្នា។

**រោគទាមឡា** [Chancroid]

រោគទាមឡា គឺជាជំងឺកាមរោគម្យ៉ាងដែលបង្កឱ្យកើតដំបៅលើប្រដាប់ភេទ។ វាអាចជាសះស្បើយ បើព្យាបាលទាន់ពេល។ រោគទាមឡាងាយច្រឡំនឹងរោគស្វាយ។

**សញ្ញារោគទាមឡា**

- ដំបៅលើប្រដាប់ភេទ ឬ រន្ធគូទ មានសភាពជាពងទន់មួយ ឬ ច្រើន ឈឺខ្លាំងពិបាកទ្រាំ ហើយងាយចេញឈាម។
- ក្រពេញរីកធំ និងឈឺចាប់ខ្លាំងអាចបង្កឡើងកូនកណ្តុរក្នុងគ្រលៀន។
- គ្រុនក្តៅតិចតួច។




| **ថ្នាំសំរាប់ព្យាបាលកាមរោគទាមឡា** | | |
|---|---|---|
| ថ្នាំពេទ្យ | លេបចំនួនប៉ុន្មាន មីលីក្រាម ឬ ក្រាម? | លេបពេលណា? ប៉ុន្មានដង និង ប៉ុន្មានថ្ងៃ? |
| ថ្នាំ **អាហ្ស៊ីត្រូម៉ីស៊ីន** = azithromycin | 1 ក្រាម (g) | លេបទាំងអស់តែម្តងគត់។ |
| **ឬ** ថ្នាំ **អេរីត្រូម៉ីស៊ីន** = erythromycin | 500 មីលីក្រាម (mg) | លេប 4 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ។ |
| **ឬ** ថ្នាំ **ស៊ីប្រូផ្លូសាកស៊ីន** = ciprofloxacin | 500 មីលីក្រាម (mg) | លេប 2 ដងក្នុងមួយថ្ងៃ សំរាប់ 3 ថ្ងៃ។ |
| (ហាមប្រើថ្នាំ **ស៊ីប្រូផ្លូសាកស៊ីន** បើអ្នកមានផ្ទៃពោះ)។ | | |
| **ចំណាំ** : បើអ្នកពុំអាចដឹងឱ្យពិតប្រាកដថា ដំបៅដែលអ្នកកើតនោះបានបង្កដោយរោគ**ទាមឡា** ឬ បើអ្នកមិនអាចទៅធ្វើតេស្តបាន ជាការប្រសើរបំផុតនោះ អ្នកក៏ត្រូវការផឹកថ្នាំព្យាបាលរោគស្វាយផងដែរ (ចូរអានទំព័រ 163)។ | | |

## ជំងឺរើមលើប្រដាប់ភេទ [genital herpes]

ជំងឺរើមកើតលើប្រដាប់ភេទ គឺជាជំងឺកាមរោគដែលបានបង្កដោយវីរុសមួយ ។ ពងបែកតូចៗដែលកើតឡើងលើប្រដាប់ភេទ គឺត្រូវបានឆ្លងពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតក្នុងពេលកំពុងរួមរក្ស ។ ជារឿយៗជំងឺរើមកើតលើប្រដាប់ភេទ អាចឆ្លងទៅកើតលើមាត់ដោយសារការរួមភេទតាមមាត់ ។ (ជំងឺរើមប្រភេទនេះ គឺខុសគ្នាពីជំងឺរើមធម្មតាដែលកើតលើមាត់ ព្រោះវាមិនឆ្លងពេលកំពុងរួមរក្ស) ។ វីរុសនៃជំងឺរើមអាចបណ្តាលឱ្យកើតដំបៅដែលជាហើយកើតមកវិញៗ ហើយវាអាចសើរើបែបនេះរាប់ខែ ឬ ឆ្នាំ ។ ជំងឺរើមគ្មានវិធីព្យាបាលឱ្យជាដាច់ស្រឡះឡើយ ប៉ុន្តែមានការព្យាបាលដែលអាចជួយឱ្យអ្នកបានធូរស្រាល ។




**រោគសញ្ញា**

- មានអារម្មណ៍ថាព្រឺស្រគៀវ, រមាស់, ឬ ឈឺលើស្បែកម្តុំប្រដាប់ភេទ ឬ ភ្លៅ ។
- ពងបែកទឹកថ្លាៗដែលឈឺខ្លាំង មើលទៅដូចដំណក់ទឹកស្រក់លើស្បែក ។ ពងទឹកថ្លាៗទាំងនេះនឹងបែក ហើយបង្កទៅជាដំបៅបើកមុខដែលឈឺចាប់យ៉ាងខ្លាំង ។

លើកដំបូងដែលអ្នកកើតដំបៅពីជំងឺរើម វាអាចកើតអស់រយៈពេលបីអាទិត្យ ឬ លើសពីនេះ ។ អ្នកអាចមានអាការៈគ្រុនក្តៅ, ឈឺក្បាល, ឈឺពេញរាងកាយ, ព្រឺរងា, និងហើមថ្នាំងជាលិកាក្នុងក្រលៀន ។ ថ្វីបើដំបៅនេះជាបាត់ទៅវិញក្តី ជំងឺឆ្លងនេះមិនជាដាច់ទេ ។ ប៉ុន្តែពេលដំបៅកើតលើកក្រោយទៀតៗ វានឹងមិនសូវខ្លាំងឡើយ ។

**ការព្យាបាល** : ចូរប្រើថ្នាំ **អាស៊ីក្លូវីរ** (acyclovir) សូមអានទំព័រ 333 ។



**ការមានផ្ទៃពោះនិងជំងឺរើម** [Pregnancy and Herpes]

ស្ត្រីមានផ្ទៃពោះដែលកើតជំងឺរើមនិងដំបៅនៅអំឡុងពេលសម្រាលកូន អាចចម្លងវីរុសនេះដល់ទារករបស់នាង ។ ករណីនេះអាចបង្កគ្រោះថ្នាក់ដល់ទារករបស់នាង ជាពិសេសបើម្តាយកើតដំបៅពីជំងឺនេះលើកទីមួយ ។ បើម្តាយធ្លាប់កើតជំងឺរើមរួចហើយ ករណីរងគ្រោះចំពោះទារកគឺមានតិចតួច ។ បើអ្នកកើតដំបៅពីជំងឺរើម ចូរព្យាយាមទៅសម្រាលកូននៅមន្ទីរពេទ្យ ។ វេជ្ជបណ្ឌិតប្រហែលជាវះកាត់យកទារកចេញ (ចូរអានទំព័រ 244 សំរាប់ការវះកាត់យកទារកចេញ) ធ្វើដូច្នេះទារកមិនឆ្លងជំងឺពីដំបៅនោះ ឬ វេជបណ្ឌិតផ្តល់ថ្នាំពេទ្យដល់ទារកក្រោយពេលទារកកើតមក ។

## ឫសដុះលើប្រដាប់ភេទ [genital warts or human papilloma virus (HPV)]

ឫសដុះលើប្រដាប់ភេទ គឺបានបង្កពីវីរុសហៅថា **វីរុសប៉ាប៉ីឡូម៉ានៃមនុស្ស** (HPV) ។ វីរុសទាំងនេះមានទ្រង់ទ្រាយដូចឫសដុះលើផ្នែកផ្សេងទៀតលើរាងកាយដែរ ។ វាគឺអាចទៅរួចដែលបុគ្គលម្នាក់អាចផ្ទុក**វីរុសប៉ាប៉ីឡូម៉ានៃមនុស្ស** ហើយមិនបានដឹង ជាពិសេសបើឫសនេះដុះខាងក្នុងរន្ធយោនី ឬ ដុះក្នុងចុងលិង្គ ។ ហើយមនុស្សខ្លះទៀតដែលផ្ទុក**វីរុសប៉ាប៉ីឡូម៉ានៃមនុស្ស** មិនមានដុះឫសអ្វីសោះ ។ ឫសនេះប្រហែលជារលាយបាត់ទៅវិញដោយគ្មានការព្យាបាល ប៉ុន្តែករណីនេះអាចទាមទារពេលយូរអង្វែង ។ តាមធម្មតាវីរុសនិងឫសទាំងនេះរាតត្បាតកាន់តែខ្លាំងបន្តទៅទៀត និងត្រូវតែព្យាបាលឱ្យជាដាច់ ។ **វីរុសប៉ាប៉ីឡូម៉ានៃមនុស្ស**ងាយឆ្លងពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតនៅអំឡុងពេលរួមរក្ស ។

**សំខាន់** : បើឫសដុះលើប្រដាប់ភេទមិនបានព្យាបាល ឫសខ្លះអាចបង្កឱ្យកើតជំងឺមហារីកនៃកស្បូន ។ បើអ្នកមានឫសដុះលើប្រដាប់ភេទ ចូរព្យាយាមទៅធ្វើតេស្ត**ប៉ាប** (អានទំព័រ 131) ដើម្បីឱ្យដឹងច្បាស់ថាតើអ្នកមានរោគសញ្ញាអ្វីមួយដែលទាក់ទិននឹង **វីរុសប៉ាប៉ីឡូម៉ានៃមនុស្ស** ឬ ជំងឺមហារីក ។

**រោគសញ្ញានៃវីរុសប៉ាប៉ីឡូម៉ានៃមនុស្ស** (HPV)

- រមាស់
- ដុំពកមានពណ៌សក្បុស ឬ ពណ៌កាហ្វេ ឈឺតិចៗ ហើយមានសភាពគគ្រាតនៅផ្ទៃខាងលើ ។

ចំពោះស្ត្រី តាមធម្មតាដុំពកៗទាំងនេះដុះត្រង់ស្បែកដែលជាបបូរជុំវិញទ្វារយោនីដល់ខាងក្នុងរន្ធយោនី និងជុំវិញរន្ធគូទ ។



ឬសដុះត្រង់ប្រដាប់ភេទស្ត្រី

ចំពោះបុរសវិញ តាមធម្មតាដុំពកៗទាំងនេះដុះលើលិង្គ ឬ ខាងក្នុងចុងលិង្គបន្តិច និងដុះលើពងស្វាស ឬ រន្ធគូទ ។



ឬសដុះត្រង់ប្រដាប់ភេទបុរស

**ការព្យាបាល**

តាមធម្មតាសំភារៈនិងឱសថសំរាប់ព្យាបាលឬស អាចរកទិញបាននៅតាមឱសថស្ថាន ឬ ហាងលក់ជាតិគីមី ។

1. ចូរលាបក្រមួនប្រេងកាត (**វ៉ាស៊ីលីន**) ឬ ប៉ូម៉ាតជាតិប្រេងលើស្បែកជុំវិញឬសនីមួយៗ ដើម្បីការពារស្បែកគ្មានជំងឺ ។
2. ចូរប្រើឈើតូចមួយ ឬ ឈើចាក់ធ្មេញឆ្កឹះយកជាតិ**អាស៊ីត ទ្រីក្លូរ៉ូសេតិច** [trichloroacetic acid (TCA)] ឬ ជាតិ**អាស៊ីត ប៊ីក្លូរ៉ូសេទិច** [bichloracetic acid (BCA)] ដែលជាក្រែមព្យាបាលឬសចំនួន 80% ទៅ 90% ដាក់ឱ្យចំឬស ។ ចូរទុកជាតិអាស៊ីតនៅលើឬសនោះទាល់តែឬសនោះទៅជាពណ៌ស ។
3. ពីរម៉ោងក្រោយមក ឬ ឆាប់ជាងនេះបើជាតិអាស៊ីតធ្វើឱ្យអ្នកឈឺផ្សារខ្លាំងទ្រាំលែងបាន ចូរលាងសំអាតវាចេញ ។

**ឬ**

ចូរលាបជាតិក្រែម**ប៉ូដូហ្វីលលីន** [podophyllin] ចំនួន 20% តាមវិធីដូចគ្នាទាល់តែឬសនោះទៅជាពណ៌កាហ្វេ (ចូរអានទំព័រ 351) ។ ចំនួន 6 ម៉ោងក្រោយមក ត្រូវលាងសំអាតជាតិក្រែម**ប៉ូដូហ្វីលលីន** ចេញ ។

ជាតិអាស៊ីតគួរតែដុតសំលាប់ឬសនោះដោយបន្សល់ទុកនូវដំបៅដែលឈឺខ្លាំងត្រង់កន្លែងឬសបានដុះ ។ ចូរថែដំបៅនោះឱ្យស្អាតនិងស្ងួតជានិច្ច ។ ដំបៅទាំងនោះគួរតែជាសះស្បើយនៅអំឡុងពេលមួយ ឬ ពីរអាទិត្យក្រោយមក ។ ចូរថែទាំពិនិត្យឱ្យដិតដល់ដើម្បីកុំឱ្យដំបៅនោះក្លាយ ។ ចូរព្យាយាមកុំរួមរ័ក្សទាល់តែដំបៅទាំងនោះជាដាច់ ប៉ុន្តែបើអ្នកត្រូវតែរួមរ័ក្ស ដៃគូ/ប្តីរបស់អ្នកត្រូវតែពាក់ស្រោមអនាម័យ ។

ធម្មតាការព្យាបាលពី-បីរយ៉ាង គឺជារឿងចាំបាច់ដើម្បីបំបាត់ឬសទាំងអស់ (វាគ្មានបញ្ហាអ្វីទាំងអស់ថាអ្នកត្រូវប្រើដំណោះស្រាយណាមួយដើម្បីព្យាបាលឬស) ។ មួយអាទិត្យក្រោយមក អ្នកអាចធ្វើការព្យាបាលជាថ្មីម្តងទៀត ។ ព្យាយាមកុំឱ្យជាតិអាស៊ីតប៉ះពាល់ដំបៅដែលជាកន្លែងឬសបានដុះពីមុន ។ បើវារលាកខ្លាំង រង់ចាំឱ្យមួយអាទិត្យកន្លងហួសសិន ហើយធ្វើការព្យាបាលម្តងទៀត ។



**ការមានផ្ទៃពោះ និង ឫស** [Pregnancy and warts]

ហាមប្រើជាតិក្រែម**ប៉ូដូហ្វីលលីន** (podophyllin) នៅអំឡុងពេលមានផ្ទៃពោះ ព្រោះវានឹងជ្រាបចូលក្នុងស្បែករបស់អ្នក ហើយអាចបង្កទុក្ខទោសដល់ទារកដែលកំពុងលូតលាស់ក្នុងផ្ទៃ ។ ឫសអាចរាលដាល និងធ្វើឱ្យធ្លាក់ឈាមនៅអំឡុងពេលមានផ្ទៃពោះ ប៉ុន្តែឫសទាំងនោះផ្ទាល់នឹងមិនបង្កទុក្ខទោសដល់ទារកឡើយ ។ ជួនកាលឫសទាំងនោះនឹងរួមតូចទៅៗ ក្រោយពីសម្រាលកូនហើយ ។

## ជំងឺថ្លើម (ខាន់លឿង, ភ្នែកលឿង) [Hepatitis (jaundice, yellow eyes)]

ជំងឺថ្លើមគឺជាបញ្ហារលាកថ្លើម តាមធម្មតាបង្កដោយវីរុសមួយ ប៉ុន្តែក៏បង្កដោយបាក់តេរី, ជាតិស្រវឹង, ឬ ជាតិគីមីពុលផងដែរ ។ ជំងឺថ្លើមបែងចែកជា 3 ប្រភេទ (អា, បេ, និង សេ) ហើយវាអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ទោះបីជាមាន ឬ គ្មានរោគសញ្ញានៃជំងឺក៏ដោយ ។



តាមធម្មតា**ជំងឺថ្លើមប្រភេទ អា** បើកើតចំពោះកុមារគឺមិនសូវជាធ្ងន់ធ្ងរឡើយ ហើយជារឿយៗជំងឺថ្លើមប្រភេទ**អា** តែងតែធ្ងន់ធ្ងរបើវាកើតចំពោះមនុស្សពេញវ័យ និងស្ត្រីមានផ្ទៃពោះ ។

**ជំងឺថ្លើមប្រភេទ បេ** គឺមានគ្រោះថ្នាក់ខ្លាំងណាស់ចំពោះមនុស្សគ្រប់រូប ។ វាអាចឈានដល់ការខូចថ្លើមមួយជីវិត (ជំងឺក្រិនថ្លើមដោយសារជាតិស្រវឹងច្រើនពេក), ជំងឺមហារីកថ្លើម និងស្លាប់ផងដែរ ។ ដូច្នេះបើអ្នកមានផ្ទៃពោះ ហើយមានរោគសញ្ញាជំងឺថ្លើមប្រភេទ**បេ** ចូរទៅសុំយោបល់ព្យាបាលពីផ្នែកវេជ្ជសាស្ត្រ ។

**ជំងឺថ្លើមប្រភេទ សេ** ក៏មានគ្រោះថ្នាក់ខ្លាំងណាស់ដែរ ហើយអាចឈានដល់ការរលាកថ្លើមទៀតផង ។ ជំងឺថ្លើមប្រភេទ**សេ** គឺជាមូលហេតុចំបងចំពោះការស្លាប់របស់មនុស្សដែលផ្ទុកវីរុសហ៊ីវ/កើតអេដស៍ ។

**រោគសញ្ញា**

- អស់កំលាំងនិងមានអារម្មណ៍ខ្សោយ ។
- ហូបម្ហូបអាហារមិនបាន ឬ មិនឃ្លាន ។
- ភ្នែក និង/ឬ ស្បែកលឿង (ជាពិសេសបាតដៃនិងបាតជើង) ។
- ឈឺក្នុងពោះ ឬ មានអាការៈក្អួតចង្អោរ ។
- ទឹកនោមមានពណ៌ចាស់ ហើយលាមកមើលទៅមានពណ៌ស ។
- ជួនកាលកើតជំងឺគ្រុនក្តៅ ។
- គ្មានរោគសញ្ញាអ្វីទាំងអស់ ។

### ការព្យាបាល



វាគ្មានថ្នាំណាមួយអាចជួយបានឡើយ ។ ការពិត ការលេបថ្នាំមួយចំនួនអាចធ្វើឱ្យថ្លើមខូចកាន់តែខ្លាំងឡើង ។ ចូរសម្រាក និង ផឹកទឹកឱ្យច្រើន ។ បើអ្នកមិនឃ្លាន ចូរព្យាយាមផឹកទឹកផ្លែឈើ, ទឹកស៊ុបដែលបានពីទឹកស្ងោរសាច់ ឬ បន្លែ ។ ដើម្បីត្រួតត្រាកុំឱ្យក្អួត ចូរផ្សើមបំពង់កជាមួយទឹកខ្ញី ឬ ទឹកកូឡា ។ ការផឹកទឹកតែដែលបានផលិតពីរុក្ខជាតិ គ្រឿងទេសដូចជា ស្លឹកផ្កា**កាំម៉ូមៀល** ក៏អាចជួយឱ្យបានធូរស្រាលដែរ ។ ចូរស្នើសុំយោបល់ពីចាស់ទុំនៅក្នុង សហគមន៍របស់អ្នក ថាតើរុក្ខជាតិប្រភេទណាស័ក្តិសិទ្ធិបំផុតដើម្បីយកវាមកដាំធ្វើទឹកតែដើម្បីផឹក ។

កាលណាអ្នកមានអារម្មណ៍មិនឃ្លានអ្វីសោះ ហាមហូបជាតិប្រូតេអ៊ីនពីសត្វ (សាច់, ត្រី, ស៊ុត) ពីព្រោះវាធ្វើឱ្យថ្លើមដែលខូចប្រឹងធ្វើការខ្លាំងពេក ។ ចៀសវាងម្ហូបអាហារដែលចំអិនដោយប្រើខ្លាញ់សត្វ ឬ ប្រេងឆា ។ ចូរហូបផ្លែឈើ និងបន្លែស្រស់ ឬ បន្លែចំហុយដែលមានជាតិប្រូតេអ៊ីនតិចជំនួសវិញ ។ ហាមផឹកគ្រឿងស្រវឹងគ្រប់ប្រភេទ យ៉ាងតិចណាស់ក៏ 6 ខែដែរ ។

### ការទប់ស្កាត់

វីរុសនៃជំងឺថ្លើមទាំងពីរប្រភេទ **បេ** និង **សេ** អាចឆ្លងពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតតាមរយៈការរួមរ័ក្ស, ការចាក់ថ្នាំដែលប្រើម្ជុលគ្មានអនាម័យ, ការបញ្ចូលឈាមដែលផ្ទុកវីរុស, ហើយអាចឆ្លងពីម្តាយទៅទារកក្នុងពេលម្តាយកំពុងសម្រាលកូន ។ ដើម្បីទប់ស្កាត់មិនឱ្យឆ្លងជំងឺថ្លើមទៅមនុស្សឯទៀត ចូរប្រើស្រោមអនាម័យជានិច្ចនៅពេលរួមរ័ក្ស (អានពីទំព័រ 181 ដល់182 និងពីទំព័រ 189 ដល់ 192) ហើយធ្វើយ៉ាងណាត្រូវតែស្ងោរឧបករណ៍ដើម្បីសំលាប់មេរោគមុនពេលប្រើដូចជា ស៊ីរ៉ាំង, ម្ជុល និងឧបករណ៍ដែលត្រូវប្រើដើម្បីកាត់ ឬ ដេរស្បែក ដូចជា (ម្ជុលសាក់ស្បែក, វះកាត់ស្បែកចុងលិង្គ, វះកាត់ដេរសំលាក, វះកាត់ប្រដាប់ភេទស្ត្រី) ។ល ។




វីរុសថ្លើមប្រភេទ **អា** ឆ្លងពីលាមកនៃបុគ្គលម្នាក់ទៅមាត់របស់បុគ្គលម្នាក់ទៀតតាមរយៈទឹកមិនស្អាត ឬ ម្ហូបអាហារគ្មានអនាម័យ ។ ដើម្បីទប់ស្កាត់កុំអ្នកឯទៀតកើតជំងឺ វាជាការសំខាន់ត្រូវធ្វើយ៉ាងណាឱ្យអ្នកជំងឺបន្ទោរបង់លាមកក្នុងបង្គន់ ឬ កន្ថោរនិងចាក់ចោលក្នុងបង្គន់ ឬ កប់ចោលឱ្យឆ្ងាយ ហើយធ្វើយ៉ាងណាលាងសំអាតអ្នកជំងឺឱ្យស្អាតជានិច្ច ។ មនុស្សគ្រប់គ្នា ទាំងអ្នកជំងឺ, ទាំងសមាជិកគ្រួសារ និងអ្នកថែទាំ ត្រូវតែព្យាយាមថែទាំខ្លួនឱ្យស្អាតជានិច្ច និងលាងដៃរបស់ខ្លួនឱ្យញឹកញាប់ជាមួយសាប៊ូនិងទឹកស្អាត ។

បច្ចុប្បន្ននេះមានថ្នាំវ៉ាក់សាំងសំរាប់ការពារជំងឺថ្លើមប្រភេទ **អា** និង **បេ** ប៉ុន្តែថ្នាំវ៉ាក់សាំងទាំងនេះប្រហែលជាថ្លៃណាស់ ឬ មិនអាចរកបានគ្រប់តំបន់ឡើយ ។ បើអ្នកមានលទ្ធភាព ចូរទៅចាក់ថ្នាំវ៉ាក់សាំងមួយនៅអំឡុងពេលអ្នកមានផ្ទៃពោះ វានឹងជួយទប់ស្កាត់វីរុសមិនឱ្យឆ្លងទៅទារករបស់អ្នក ។

## អ្វីៗដែលត្រូវធ្វើបើអ្នកមានជំងឺកាមរោគ

បើអ្នក ឬ ដៃគូ/ប្ដីរបស់អ្នកមានរោគសញ្ញាកាមរោគ :-

- ចាប់ផ្ដើមព្យាបាលជាបន្ទាន់ ។ ការព្យាបាលទាន់ពេលវេលានឹងការពារអ្នកពីបញ្ហាធ្ងន់ធ្ងរជាច្រើនទៀតនៅពេលខាងមុខ ហើយទប់ស្កាត់ការចម្លងជំងឺទៅឱ្យបុគ្គលផ្សេងទៀត ។
- ទៅធ្វើតេស្ត បើអាចធ្វើបាន ។ ចូរទៅគ្លីនិក ឬ មណ្ឌលសុខភាពកន្លែងដែលអ្នកទទួលបានការធ្វើតេស្តដើម្បីឱ្យដឹងថា អ្នកកើតជំងឺកាមរោគណាមួយ ។ តាមវិធីនេះ អ្នកមិនចាំបាច់លេបថ្នាំដែលអ្នកមិនត្រូវការ ។ បើអ្នកគ្មានវិធីណាអាចទទួលបានការធ្វើតេស្ត អ្នកប្រហែលជាត្រូវលេបថ្នាំពីរ-បីមុខចូលគ្នា ។ ចូរព្យាយាមនិយាយជាមួយបុគ្គលិកសុខាភិបាលមានជំនាញអំពីការព្យាបាល ។




- ចូរជួយដៃគូ/ប្ដីរបស់អ្នកឱ្យទទួលបានការព្យាបាលក្នុងពេលទន្ទឹមគ្នានឹងអ្នក ។ បើគាត់មិនបានព្យាបាល គាត់នឹងចម្លងជំងឺនោះឱ្យអ្នកម្ដងទៀត បើអ្នកមានការរួមភេទ ។ ចូរជួយជំរុញឱ្យគាត់លេបថ្នាំត្រឹមត្រូវ ឬ ទៅជួបបុគ្គលិកសុខាភិបាលម្នាក់ ។
- ចូរធ្វើឱ្យប្រាកដថា អ្នកត្រូវតែលេបថ្នាំទាំងនោះឱ្យចប់សព្វគ្រប់ ថ្វីបើរោគសញ្ញានោះចាប់ផ្ដើមជាបាត់ទៅវិញក៏ដោយ ។ ហាមទិញថ្នាំតែមួយផ្នែក ។ អ្នក ឬ ដៃគូ/ប្ដីរបស់អ្នកនឹងមិនជាដាច់ស្រឡះឡើយ ដរាបណាអ្នកនិងដៃគូ/ប្ដីរបស់អ្នកបានលេបថ្នាំគ្រប់ចំនួនកំណត់ (ចូរអានទំព័រ 327) ។ ចូរអនុវត្តការរួមភេទដែលមានសុវត្ថិភាព ។ បើអ្នកមិនការពារខ្លួនឯងជានិច្ចជាកាល អ្នកអាចឆ្លងជំងឺកាមរោគមួយទៀត (ចូរអានពីទំព័រ 180 ដល់ 182) ។

## តើអ្វីទៅជាវីរុសហ៊ីវ/អេដស៍? [HIV/AIDS]

**វីរុសហ៊ីវ (វីរុសបំផ្លាញប្រព័ន្ធការពាររោគក្នុងរាងកាយមនុស្ស)** គឺជាមេរោគល្អិតៗមិនអាចមើលឃើញដែលធ្វើឱ្យប្រព័ន្ធការពាររោគក្នុងរាងកាយរបស់អ្នកចុះខ្សោយ ផ្នែកនៃរាងកាយដែលទប់ស្កាត់ប្រឆាំងជំងឺនិងរោគឆ្លងទាំងឡាយ ។ ភាគច្រើនបំផុត វីរុសហ៊ីវឆ្លងពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតនៅអំឡុងពេលរួមភេទ ។ បើបុរសម្នាក់ចម្លងវីរុសហ៊ីវដល់ស្ត្រីមានផ្ទៃពោះម្នាក់ ឬ បើស្ត្រីមានផ្ទៃពោះម្នាក់បានផ្ទុកវីរុសហ៊ីវរួចហើយនោះ វីរុសក៏អាចឆ្លងទៅទារកផងដែរនៅអំឡុងពេលស្ត្រីកំពុងមានផ្ទៃពោះ, អំឡុងពេលស្ត្រីសម្រាលកូន, ឬ អំឡុងរយៈពេលស្ត្រីបំបៅដោះកូន ។ សំរាប់ព័ត៌មានបន្ថែមអំពីបុគ្គលម្នាក់អាច ឬ មិនអាចឆ្លងវីរុសហ៊ីវ ចូរអានពីទំព័រ 170 ដល់ 171 ។



**អេដស៍ (ប្រព័ន្ធការពាររោគបានចុះខ្សោយដោយសហានិមិត្តហេតុ)** គឺជាជំងឺដែលបានកើតមួយរយៈពេលមកហើយ បន្ទាប់ពីបុគ្គលម្នាក់បានផ្ទុកវីរុសហ៊ីវរួចហើយ ។ យើងអាចនិយាយបានថា អ្នកកើតជំងឺអេដស៍គឺនៅពេលបុគ្គលនោះចាប់មានបញ្ហាសុខភាពទូទៅញឹកញាប់ច្រើនជាងធម្មតា ។ រោគសញ្ញានៃជំងឺអេដស៍មួយចំនួនគឺស្រកទំងន់, កើតជំងឺរាកដែលមិនជាដាច់, ក្អកខ្លាំង, បែកញើសជោគៗពេលយប់, រាគរូស, កើតកន្ទួលរមាស់ស្បែក, គ្រុនក្ដៅ, ធ្លាក់សពីរន្ធយោនី, ឬ អស់កំលាំងល្ហិតល្ហៃគ្រប់ពេល ។ ប៉ុន្តែបញ្ហាទាំងនេះអាចបានបង្កពីមូលហេតុផ្សេងៗទៀត ។ អ្នកពុំអាចដឹងប្រាកដថាបុគ្គលម្នាក់មានវីរុសហ៊ីវ/ អេដស៍ដោយគ្មានធ្វើការពិនិត្យឈាមតាមវិធីធ្វើតេស្តពិសេសឡើយ ចូរអានទំព័រ 172 ។

ដោយសារតែប្រព័ន្ធការពាររោគរបស់បុគ្គលដែលផ្ទុកវីរុសហ៊ីវបានចុះខ្សោយបន្តិចម្តងៗជាមួយនឹងជំងឺនីមួយៗ ដូច្នេះហើយរាងកាយបុគ្គលនោះមានលទ្ធភាពតិចតួចក្នុងការទប់ទល់នឹងជំងឺ និងទ្រទ្រង់រាងកាយឱ្យគ្រាន់បើឡើងវិញ។ បញ្ហានេះនឹងចេះតែកើតមានទាល់តែរាងកាយបុគ្គលនោះខ្សោយលែងត្រដររស់តទៅទៀតបាន ហើយបុគ្គលនោះនឹងបាត់បង់ជីវិត។ មនុស្សណាក៏ដោយអាចឆ្លងវីរុសហ៊ីវ/អេដស៍ រួមទាំងជនពិការ និង ជនមិនពិការផងដែរ។

មនុស្សខ្លះស្លាប់ដោយសារជំងឺអេដស៍យ៉ាងលឿនបំផុត ក្រោយពីបានផ្ទុកវីរុសហ៊ីវ។ ប៉ុន្តែសំរាប់មនុស្សជាច្រើននាក់បានផ្ទុកវីរុសហ៊ីវរាប់ឆ្នាំ ទើបពួកគេចាប់ផ្តើមឈឺដោយសារជំងឺអេដស៍។ នេះមានន័យថា បុគ្គលម្នាក់អាចផ្ទុកវីរុសហ៊ីវ ហើយពុំបានដឹងដោយសារតែគាត់មានអារម្មណ៍ថាខ្លួនឯងមាំមួន។ ទោះជាពួកគេមានអារម្មណ៍យ៉ាងណាក៏ដោយ ពួកគេអាចចម្លងវីរុសហ៊ីវដល់បុគ្គលម្នាក់ទៀតយ៉ាងឆាប់បំផុតក្នុងពេលដែលពួកគេបានផ្ទុកវីរុសនោះភ្លាមៗ។ វិធីដែលអាចដឹងឱ្យច្បាស់ថាអ្នកផ្ទុកវីរុសមានតែម្យ៉ាងគត់ គឺធ្វើតេស្តឈាមរបស់អ្នក។ ការធ្វើតេស្តឈាមអាចធ្វើបាននៅឯគ្លីនិក និង មន្ទីរពេទ្យនានា។



ថ្នាំពេទ្យហៅថា **អង់ទីរ៉េត្រូវីរ៉ាល់** [antiretrovirals (ARVs)] អាចជួយពន្យារពេលដល់មនុស្សផ្ទុកវីរុសហ៊ីវ/អេដស៍ឱ្យរស់នៅបានយូរ និងទ្រទ្រង់សុខភាពបានគ្រាន់បើជាងមុន។ ថ្នាំទាំងនេះមិនបានសំលាប់វីរុសហ៊ីវ ឬ ធ្វើឱ្យជំងឺអេដស៍ជាសះស្បើយឡើយ ប៉ុន្តែវាជួយសម្រួលឱ្យអ្នករស់នៅបានស្រួលជាងមុនជាមួយនឹងជំងឺនេះ។ ចំពោះស្ត្រីមានផ្ទៃពោះ ការទទួលបានថ្នាំ **អង់ទីរ៉េត្រូវីរ៉ាល់** អាចទប់ស្កាត់វីរុសហ៊ីវមិនឱ្យឆ្លងពីម្តាយទៅកូនក្នុងផ្ទៃ។ វាគួរឱ្យស្តាយ ថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់** អាចថ្លៃខ្លាំងណាស់ និងប្រហែលជាពិបាករកបាននៅក្នុងប្រទេសមួយចំនួន។ សំរាប់ព័ត៌មានអំពីថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់** ចូរអានទំព័រ 176។

## វិធីដែលវីរុសហ៊ីវ/អេដស៍ឆ្លង

វីរុសដែលបង្កវីរុសហ៊ីវ/អេដស៍ វារស់នៅក្នុងទឹកអង្គធាតុជាក់លាក់នៃរាងកាយរបស់មនុស្សដែលផ្ទុកវីរុសហ៊ីវ ដូចជាឈាម, ទឹកកាមរបស់បុរស, និងជាតិសើមក្នុងរន្ធយោនីរបស់ស្ត្រី។ វីរុសគឺឆ្លងនៅពេលទឹកអង្គធាតុទាំងនេះជ្រៀតចូលក្នុងរាងកាយរបស់មនុស្សម្នាក់ទៀត។ វីរុសហ៊ីវអាចបានឆ្លងដោយ :-

រួមរ័ក្សនឹងអ្នកដែលផ្ទុកវីរុសហ៊ីវ បើបុគ្គលនោះមិនប្រើស្រោមអនាម័យ



ប្រើម្ជុល ឬ ឧបករណ៍ដែលចោះ ឬ កាត់ស្បែកដែលមិនបានសំលាប់មេរោគ



ឈាមមានផ្ទុកវីរុសដែលបានហូរចូលស្នាមរបួស ឬ ដំបៅបើកមុខនៃមនុស្សម្នាក់ទៀត។



ម្តាយដែលផ្ទុកវីរុសចម្លងទៅកូនតាមរយៈការមានផ្ទៃពោះ, ពេលសម្រាលកូន ឬ ពេលបំបៅដោះកូន។



នៅតាមកន្លែងដែលគ្មានការធ្វើតេស្តឈាមសំរាប់វីរុសហ៊ីវ មនុស្សម្នាក់អាចឆ្លងវីរុសហ៊ីវពីការបញ្ចូលឈាម។ សំរាប់ព័ត៌មានអំពីការទប់ស្កាត់វីរុសហ៊ីវ/អេដស៍ ចូរអានពីទំព័រ 179 ដល់ 182។

### របៀបដែលវីរុសហ៊ីវ/អេដស៍មិនឆ្លង

វីរុសហ៊ីវមិនអាចរស់នៅខាងក្រៅរាងកាយមនុស្សច្រើនជាងពីរ-បីនាទីឡើយ ។ វាមិនអាចរស់ដោយខ្លួនវានៅក្នុងខ្យល់ ឬ ក្នុងទឹកឡើយ ។

- ការប៉ះពាល់, ការឱប, ឬ ការថើប ។
- ការហូបអាហាររួមគ្នា ។
- ការដេកគ្រែមួយរួមគ្នា ។
- ការប្រើកំណាត់, សំភារៈដំណេក ( កំរាល, ពូក, មុង, ភួយ, ខ្នើយ) ឬ បង្គន់រួមគ្នា ។
- សត្វល្អិតទិច ឬ ខាំ ។



វីរុសហ៊ីវ/អេដស៍មិនឆ្លងតាមការប៉ះពាល់គ្នាឡើយ។

### របៀបដែលវីរុសហ៊ីវ/អេដស៍មានឥទ្ធិពលលើស្ត្រី

ស្ត្រីដែលផ្ទុកវីរុសហ៊ីវ ជារឿយៗធ្លាក់ខ្លួនឈឺជាមួយជំងឺអេដស៍លឿនជាងបុរស ។ ការខ្វះខាតចំណីអាហារត្រឹមត្រូវ និងការមានកូនអាចធ្វើឱ្យរាងកាយស្ត្រីមានលទ្ធភាពតិចតួចក្នុងការទប់ទល់នឹងជំងឺ ។ ស្ត្រីក៏ងាយឆ្លងវីរុសហ៊ីវជាងបុរសផងដែរ ។ ពេលទឹកកាមរបស់បុរសចូលក្នុងរាងកាយរបស់ស្ត្រីនៅអំឡុងពេលរួមរ័ក្ស វាអាចឆ្លងបានយ៉ាងងាយតាមរយៈរន្ធយោនី ឬ កស្បូនចូលទៅក្នុងឈាមរបស់នាង ជាពិសេសបើស្បែកមានដាច់រលាត់ ឬ ដំបៅ ។ ករណីនេះអាចកើតឡើង ទោះបីជានាងមាន ឬ គ្មានពិការភាពក៏ដោយ ។

**គំនិតដែលបង្កមហន្តរាយអំពីវីរុសហ៊ីវ/អេដស៍ និងស្ត្រីពិការ**

គំនិតដ៏ខុសទំនងនិងបង្កទុក្ខទោសខ្លាំងបំផុតអំពីវីរុសហ៊ីវ/អេដស៍គឺមានជំនឿថា បើបុគ្គលដែលផ្ទុកវីរុសហ៊ីវ/អេដស៍បានរួមរ័ក្សជាមួយមនុស្សម្នាក់ផ្សេងទៀតដែលនៅក្រមុំព្រហ្មចារីយ៍ នោះបុគ្គលដែលផ្ទុកវីរុសហ៊ីវ/អេដស៍នឹងបានជាដាច់ពីជំងឺនេះ ។ ដោយសារតែគំនិតដ៏ចម្លែងនេះ បុរសដែលផ្ទុកវីរុសហ៊ីវ/អេដស៍អាចទៅរកស្ត្រីពិការ បើបុរសនោះគិតថា ពីព្រោះតែនាងជាស្ត្រីពិការ នាងពិតជានៅក្រមុំព្រហ្មចារីយ៍ ហើយអាចធ្វើឱ្យគាត់ជាដាច់ពីជំងឺនេះ ។ រឿងនេះមិនពិតឡើយ ។ ការរួមរ័ក្សជាមួយស្រីក្រមុំព្រហ្មចារីយ៍ គឺបានត្រឹមតែចម្លងវីរុសហ៊ីវ/អេដស៍ដល់ស្រីក្រមុំព្រហ្មចារីយ៍ម្នាក់តែប៉ុណ្ណោះ ។ វាមិនបានធ្វើឱ្យបុគ្គលដែលផ្ទុកវីរុសហ៊ីវ/អេដស៍មានសុខភាពមាំមួនដូចដើមវិញឡើយ ។



## ការដឹងឱ្យច្បាស់បើអ្នកមានផ្ទុកវីរុសហ៊ីវ

### ការធ្វើតេស្តពិនិត្យវីរុសហ៊ីវ

ពេលវីរុសហ៊ីវជ្រៀតចូលក្នុងរាងកាយមនុស្ស ប្រព័ន្ធការពាររោគក្នុងខ្លួនមនុស្សចាប់ផ្តើមផលិត**អង់ទីគ័រ**ភ្លាមដើម្បីប្រឆាំងនឹងវីរុស ។ នៅរវាងពី 2 ទៅ 4 អាទិត្យ ការធ្វើតេស្តវីរុសហ៊ីវអាចរកឃើញអង់ទីគ័រទាំងនេះនៅក្នុងឈាម ។ នេះជាវិធីតែម្យ៉ាងគត់ដែលបុគ្គលម្នាក់អាចដឹងច្បាស់ថា ខ្លួនឯងបានឆ្លងវីរុសហ៊ីវ ។

**លទ្ធផលវិជ្ជមានពីការធ្វើតេស្តវីរុសហ៊ីវ**មានន័យថា អ្នកបានឆ្លងវីរុស ហើយរាងកាយរបស់អ្នកបានផលិតអង់ទីគ័រចំពោះវីរុសហ៊ីវ ។ ថ្វីបើអ្នកមានអារម្មណ៍ល្អក្នុងខ្លួនក៏ដោយ អ្នកអាចចម្លងវីរុសនេះដល់មនុស្សឯទៀត ។

**លទ្ធផលអវិជ្ជមានពីការធ្វើតេស្តវីរុសហ៊ីវ** មានន័យ 1 ក្នុងចំណោម 2 យ៉ាង :-

- អ្នកមិនបានឆ្លងវីរុសហ៊ីវ ឬ
- អ្នកទើបតែឆ្លង ប៉ុន្តែរាងកាយអ្នកមិនទាន់ផលិតអង់ទីគ័រគ្រប់គ្រាន់ចំពោះវីរុសហ៊ីវដើម្បីរកវាឃើញក្នុងពេលធ្វើតេស្ត ។

បើអ្នកបានទៅធ្វើតេស្តវីរុសហ៊ីវ ហើយលទ្ធផលបង្ហាញការអវិជ្ជមាន ប៉ុន្តែអ្នកគិតថាខ្លួនឯងបានឆ្លងវីរុស អ្នកគួរតែធ្វើតេស្តម្តងទៀតក្នុងរវាង 6 អាទិត្យក្រោយមក ។ ជួនកាលលទ្ធផលធ្វើតេស្តវីរុសហ៊ីវវិជ្ជមាន ក៏ត្រូវការទៅធ្វើតេស្តឡើងវិញម្តងទៀតដែរ ។ បុគ្គលិកសុខាភិបាលមានបទពិសោធន៍អាចជួយអ្នកឱ្យសំរេចចិត្ត ។

**ចំណាំ** : ការធ្វើតេស្តនិងការពិគ្រោះបញ្ហាសំរាប់វីរុសហ៊ីវ តាមធម្មតាបានធ្វើឡើងក្នុងពេលតែមួយ ហើយសេវាបំរើបែបនេះបានបង្កើតច្រើនឡើង១ ដើម្បីបំរើតម្រូវការបុគ្គលមានបញ្ហានេះ ។ ចូរសាកសួរបុគ្គលិកសុខាភិបាលនៅក្នុងសហគមន៍របស់អ្នកតើកន្លែងណាដែលអ្នកអាចទៅធ្វើតេស្តបាន ។ នៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យជាច្រើន ការធ្វើតេស្តវីរុសហ៊ីវ គឺមានបំរើយ៉ាងរហ័សក្នុងតម្លៃទាប ឬមិនបង់ថវិកាអ្វីទាំងអស់ ។




តាមធម្មតាអ្នកអាចទទួលលទ្ធផលតេស្តក្នុងថ្ងៃដដែលនោះ ។ មជ្ឈមណ្ឌលធ្វើតេស្តមួយចំនួនមានព័ត៌មានជាភាសាប្រៃយ៍ និងខ្លះទៀតមានជាភាសាសញ្ញា ។

**សំខាន់** : អ្នកអាចចម្លងវីរុសហ៊ីវទៅឱ្យមនុស្សឯទៀតបានយ៉ាងឆាប់រហ័ស គឺក្នុងពេលអ្នកបានឆ្លងវាភ្លាម១ ថ្វីបើអ្នកមើលទៅមានសុខភាពមាំមួននិងមានអារម្មណ៍ល្អក៏ដោយ ។ អ្នកមិនអាចស្មានពីការសម្លឹងមើលមនុស្សតែសំបកក្រៅ ថាតើបុរស ឬ ស្ត្រីនោះមាន ឬ គ្មានវីរុសហ៊ីវឡើយ ។ វិធីដែលអាចដឹងឱ្យច្បាស់ថា អ្នកបានឆ្លងមានតែម្យ៉ាងគត់ គឺទៅធ្វើតេស្តវីរុសហ៊ីវ ។

## ការពិគ្រោះបញ្ហា

ការធ្វើតេស្តវីរុសហ៊ីវគួរតែត្រូវបានធ្វើឡើង :-

- ដោយមានការយល់ព្រមពីអ្នក ។
- ដោយមានការពិគ្រោះបញ្ហាមុនពេល និង ក្រោយពេលធ្វើតេស្ត ។
- ដោយគោរពរក្សាការសំងាត់ដែលជាភាពឯកជនរបស់បុគ្គលផ្ទាល់ ហើយមានតែរូបអ្នកផ្ទាល់និងបុគ្គលណាដែលអ្នកចង់ប្រាប់ឱ្យដឹងអំពីលទ្ធផលតែប៉ុណ្ណោះ ។

អ្នកពិគ្រោះបញ្ហាដែលមានជំនាញខាងវីរុសហ៊ីវ/អេដស៍ អាចជួយអ្នកឱ្យសំរេចចិត្តកាលណាអ្នកត្រូវការទៅធ្វើតេស្តសំរាប់វីរុសហ៊ីវ ។ បើលទ្ធផលតេស្តរបស់អ្នកបានបង្ហាញភាពវិជ្ជមាន អ្នកពិគ្រោះបញ្ហាអាចជួយអ្នកឱ្យសំរេចចិត្តថា នរណាខ្លះដែលអ្នកត្រូវតែប្រាប់ ហើយវិធីណាខ្លះដែលជួយអ្នកឱ្យចេះតទល់ជាមួយការផ្លាស់ប្តូរនេះក្នុងជីវិតរបស់អ្នក ។



ការពិគ្រោះបញ្ហាសំរាប់បុគ្គលផ្ទុកវីរុសហ៊ីវនិងក្រុមគ្រួសាររបស់ពួកគេ អាចមានន័យចំពោះភាពខុសគ្នារវាងក្តីសង្ឃឹម និងអស់សង្ឃឹម ។ ដូចស្ត្រីម្នាក់ដែលផ្ទុកវីរុសហ៊ីវនៅប្រទេស**កេនយ៉ា** បាននិយាយថា "ពេលអ្នកបានជួបនឹងអ្នកពិគ្រោះបញ្ហាល្អម្នាក់ អ្នកមានអារម្មណ៍ដូចខ្លួនឯងបានជាសះស្បើយអញ្ចឹង ។"

### ការការពាររឿងសំខាត់ផ្ទាល់ខ្លួនដែលជាភាពឯកជនរបស់អ្នក

ស្ត្រីណាក៏ដោយគួរតែអាចធ្វើការសំរេចចិត្តដោយខ្លួនឯងផ្ទាល់ ថាតើនាងត្រូវប្រាប់នរណាខ្លះឱ្យដឹងអំពីរឿងនាងផ្ទុកវីរុសហ៊ីវ និងវិធីដែលត្រូវប្រាប់ពួកគេ ។ វាជាការសំខាន់សំរាប់ស្ត្រីដើម្បីនិយាយជាមួយដៃគូដែលនាងបានរួមរ័ក្សជាមួយ ឬ ដៃគូ/ប្តី ធ្វើដូច្នេះ ពួកគេអាចទៅធ្វើតេស្ត ឬ ការពារសុខភាពរបស់ខ្លួនផងដែរ ។ ស្ត្រីជាច្រើននាក់បាននិយាយប្រាប់ក្រុមគ្រួសាររបស់ខ្លួន និងមនុស្សដែលគាំទ្រពួកគេ ។ ប៉ុន្តែជារឿយៗ ស្ត្រីខ្លាចមនុស្សទាំងឡាយក្នុងសហគមន៍ដឹងរឿងរបស់នាង ។

វាអាចជាការពិបាកចំពោះស្ត្រីពិការដើម្បីទទួលបានការសន្ទនាស្ងាត់ៗជាមួយបុគ្គលិកសុខាភិបាលម្នាក់ ។ នេះប្រហែលជាដោយសារ :-

- បុគ្គលិកសុខាភិបាលមិនធ្លាប់បានរៀនសូត្រថា ស្ត្រីពិការម្នាក់គួរត្រូវបានគោរពប្រត្តិបតិដូចស្ត្រីផ្សេងទៀតដែរ ។
- បុគ្គលិកសុខាភិបាលនឹងប្រាប់ក្រុមគ្រួសារ ឬ មិត្តភក្តិរបស់ស្ត្រីពិការជំនួសសាម៉ីខ្លួនអំពីបញ្ហាសុខភាពរបស់ស្ត្រីពិការ រួមទាំងវីរុសហ៊ីវ ឬ ជំងឺកាមរោគណាមួយដោយមិនប្រាប់ស្ត្រីពិការផ្ទាល់ឱ្យដឹង ។ ករណីនេះជាការពិត ជាពិសេសកាលបើស្ត្រីពិការពិបាកប្រាស្រ័យទាក់ទង ។
- ក្រុមគ្រួសាររបស់ស្ត្រីមិនព្រមឱ្យនាងជួបបុគ្គលិកសុខាភិបាលតែម្នាក់ឯងឡើយ ។

ដោយសារតែខ្ញុំជាមនុស្សថ្លង់ ជារឿយៗ ខ្ញុំមានបញ្ហានឹងរឿងផ្ទាល់ខ្លួន ជាពិសេស ពេលខ្ញុំប្រើអ្នកបកប្រែដើម្បីនិយាយនឹង បុគ្គលិកសុខាភិបាល។ អ្នកបកប្រែដែលធ្វើ ការនៅគ្លីនិកបានដឹងទាំងអស់អំពីអ្វីៗដែល បុគ្គលិកសុខាភិបាលនិងខ្ញុំនិយាយគ្នាអំពី ការសំងាត់ដែលរឿងផ្ទាល់ខ្លួន។ នាងមិន ដែលប្រាប់អ្នកផ្សេងទៀតឡើយ សូម្បីតែ បុគ្គលិកសុខាភិបាលឯទៀត អំពីអ្វីៗដែល យើងបាននិយាយ។



បើខ្ញុំយកអ្នកបកប្រែផ្ទាល់ខ្លួនទៅជាមួយ ខ្ញុំរំលឹកនាងជាមុនថាអ្វីៗដែលខ្ញុំនិយាយ ជាមួយបុគ្គលិកសុខាភិបាល គឺជារឿងផ្ទាល់ ខ្លួនរបស់ខ្ញុំ។ ខ្ញុំព្យាយាមធ្វើយ៉ាងណាឱ្យ អ្នកបកប្រែបានយល់ថា លទ្ធផលពីការធ្វើ តេស្តគឺជារឿងសំងាត់ផ្ទាល់ខ្លួនខ្ញុំ។ ខ្ញុំស្នើឱ្យ នាងមិនឱ្យប្រាប់មនុស្សផ្សេងដោយគ្មាន ការយល់ព្រមពីខ្ញុំ ទោះបីជាក្រុមគ្រួសារ របស់ខ្ញុំក៏ដោយ។

### ទៅរកការជួយសំរាប់បញ្ហាសុខភាពដែលបានបង្កដោយវីរុសហ៊ីវ/អេដស៍

បុគ្គលម្នាក់ដែលផ្ទុកវីរុសហ៊ីវអាចមានជំងឺដោយងាយពីបញ្ហាសុខភាពទូទៅផ្សេងៗ ។ នេះជាព័ត៌មានទូទៅខ្លះៗអំពីបញ្ហាមួយចំនួន ប៉ុន្តែជាការល្អបំផុតក្នុងការនិយាយជាមួយបុគ្គលិកសុខាភិបាល ឬ អានសៀវភៅដូចជា **សៀវភៅស្តីពីវីរុសហ៊ីវ**, និង **សៀវភៅស្តីពីសុខភាពនិងសហគមន៍របស់អ្នក** សំរាប់ជួយជាព័ត៌មានបន្ថែម ។ ភាគច្រើនបំផុតបញ្ហាសុខភាពទូទៅបានបង្កពីវីរុសហ៊ីវ/អេដស៍ គឺ :-

**ជំងឺគ្រុនក្តៅ** – ជារឿយៗគ្រុនក្តៅតែងឈឺសារចុះសារឡើង ។ វាពិបាកដឹងណាស់ថា ជំងឺគ្រុនក្តៅនោះបង្កពីជំងឺឆ្លងដែលអាចព្យាបាលបាន ដូចជាជំងឺរបេង, ជំងឺរលាកក្នុងស្បូន, ឬ ជំងឺគ្រុនចាញ់ ឬ វាបង្កពីវីរុសហ៊ីវនោះផ្ទាល់ ។ បើជំងឺគ្រុនក្តៅបានបង្កពីជំងឺឆ្លងមួយបន្ទាប់មកជំងឺឆ្លងនោះត្រូវតែបានព្យាបាលឱ្យពិតប្រាកដ ។



**ជំងឺរាគរូស :** ជំងឺរាគអាចរើសារចុះសារឡើង ហើយពិបាកព្យាបាល ។ មូលហេតុទូទៅដែលបណ្ដាលឱ្យរាគរូសចំពោះអ្នកជំងឺអេដស៍ គឺជំងឺឆ្លងដោយសារវីរុសហ៊ីវ ឬ ឥទ្ធិពលបង្កពីថ្នាំពេទ្យមួយចំនួន ។

**កន្ទួលនិងរមាស់ស្បែក :** ជារឿយៗ វាជាការពិបាកដឹងណាស់ថាអ្វីទៅដែលបានបង្កឱ្យស្បែកកន្ទួលនិងរមាស់ ។ បញ្ហាជំងឺសើស្បែកមួយចំនួនបានពាក់ព័ន្ធនឹងវីរុសហ៊ីវ/អេដស៍អាចបានបង្កដោយ :-

- ការប្រតិកម្មចំពោះថ្នាំពេទ្យ
- វាធ្វើឱ្យសាច់ដុះឡើងក្រមរពណ៌កាហ្វេ ឬ ស្វាយ កើតលើមាត់ ឬ ស្បែកដែលបង្កពីមហារីកនៃសរសៃឈាម/ថ្នាំងជាលិកាហៅថា **កាប៉ូស៊ីនៃសារកូម៉ា** (Kaposi's sarcoma) ។
- រើមដឺរ (herpes zoster/shingles) ដែលជាធម្មតាចាប់ផ្ដើមជាមួយពងទឹកថ្លា, ឈឺខ្លាំង ហើយបែកចំហមុខ ។ ធម្មតាវាកើតលើមុខ, ខ្នង, និងដើមទ្រូង ។

**ចង្អោរនិងក្អួត :** ករណីនេះអាចបង្កមកពីជំងឺឆ្លង, ថ្នាំពេទ្យមួយចំនួន, បញ្ហាពោះនិងពោះវៀន ឬ វីរុសហ៊ីវខ្លួនវាផ្ទាល់ ។



**ក្អក :** ករណីនេះអាចជារោគសញ្ញានៃបញ្ហាសួត, ដូចជាជំងឺរលាកសួត ឬ របេង ។ កាលណាសួតបានរលាក ឬ ឆ្លងជំងឺ សួតផលិតជាតិរអិលដូចសំបោរកាន់តែច្រើនថែមទៀតដែលវាបណ្ដាលឱ្យអ្នកជំងឺក្អក ។

**របេង** គឺជាជំងឺឆ្លងកាចសាហាវបានបង្កដោយមេរោគដែលធម្មតាប៉ះពាល់ដល់សួត ។ រោគសញ្ញាជំងឺអេដស៍ និងជំងឺរបេងគឺស្រដៀងគ្នា ប៉ុន្តែជំងឺទាំងពីរនេះគឺខុសប្លែកពីគ្នា ។ ស្ត្រី, បុរស, និងកុមារស្ទើរតែទាំងអស់ដែលកើតជំងឺរបេង គឺមិនបានកើតជំងឺអេដស៍ឡើយ ។ ប៉ុន្តែបុគ្គលម្នាក់ដែលកើតជំងឺអេដស៍អាចកើតជំងឺរបេងយ៉ាងងាយ ដោយសាររាងកាយរបស់គាត់ចុះខ្សោយនឹងការប្រឆាំងវា ។ មនុស្សមួយនាក់ក្នុងចំណោមមនុស្ស 3នាក់ដែលកើតជំងឺអេដស៍ គឺជំងឺរបេងទេវិញទេដែលបានសំលាប់ពួកគេ ។

**បញ្ហាមាត់និងបំពង់ក :** បញ្ហាអាចរួមបញ្ចូលទាំង :- រលាកខ្លាំង, ប្រេះ, ដំបៅ, ពងបែក, ហើយអណ្ដាតកើតជ្រាំងពណ៌ស (ជ្រាំងអណ្ដាត ចូរអានទំព័រ 260) ។

**ចុះទំងន់និងទទួលម្ហូបអាហារមិនគ្រប់គ្រាន់ :** អ្នកកើតអេដស៍អាចទៅជាខ្វះជាតិម្ហូបអាហារក្នុងខ្លួន ដោយសារគាត់មានជំងឺប្រចាំកាយពីជំងឺរាគរូស ដែលរារាំងរាងកាយពីការស្រូបយកជាតិចំណីអាហារដើម្បីទ្រទ្រង់រាងកាយឱ្យធំធាត់, ពីការបាត់បង់ការឃ្លានចំណីអាហារ, និងពីបញ្ហាកើតជំងឺមាត់ដែលធ្វើឱ្យគាត់ពិបាកហូបចុក ។ ការចុះទំងន់គឺជារឿងធម្មតាចំពោះអ្នកផ្ទុកវីរុសហ៊ីវ ដែលនៅតំបន់មួយចំនួននៃទ្វីបអាហ្វ្រិក, ជំងឺអេដស៍ត្រូវបានគេហៅថា "ជំងឺស្គម" ។

## ការព្យាបាលសំរាប់វីរុសហ៊ីវ/អេដស៍



នៅក្នុងប្រព័ន្ធព្យាបាលតាមបែបវិទ្យាសាស្ត្រថ្នាំពេទ្យ ឬ ថ្នាំបុរាណ មិនទាន់បានរកឃើញអ្វីមួយដែលអាចព្យាបាលរោគអេដស៍ឱ្យជាដាច់ស្រឡះឡើយ ។ ប៉ុន្តែមានវិធីជាច្រើនយ៉ាងដែលអាចធ្វើបានដើម្បីជួយបុគ្គលកើតជំងឺអេដស៍ ។ ទឹកស្អាត, ម្ហូបអាហារមានជីវជាតិ, សំលៀកបំពាក់បោកគក់ស្អាតបាត, កន្លែងដេកសម្រាកមានអនាម័យស្អាតបាត, និងបង្កបង្កើតទំនាក់ទំនងកក់ក្តៅដោយក្តីស្រឡាញ់ជាមួយមិត្តភក្តិ និងក្រុមគ្រួសារទាំងអស់ ដែលអាចជួយឱ្យអ្នកជំងឺអេដស៍រក្សាសុខភាពបានមាំមួន ។ ម្ហូបអាហារទាំងឡាយណាដែលល្អសំរាប់បុគ្គលដែលមានសុខភាពមាំមួន ម្ហូបអាហារទាំងនោះក៏ល្អសំរាប់អ្នកមានជំងឺដែរ (ចូរអានពីទំព័រ 177 ដល់ 178) ។

ថ្វីបើគ្មានអ្វីព្យាបាលជំងឺអេដស៍ឱ្យជាដាច់ក៏ដោយ ថ្នាំពេទ្យ**អង់ទីរ៉េត្រូវីរ៉ាល់ (អេ-អរ-វី)**[antiretroviral (ARVs)] ឥឡូវនេះត្រូវបានប្រើយ៉ាងជោគជ័យដើម្បីទ្រទ្រង់សុខភាពអ្នកជំងឺអេដស៍ ។ **អេ-អរ-វី** ជួយពង្រឹងប្រព័ន្ធស៊ាំរោគក្នុងរាងកាយអ្នកជំងឺ ដូច្នេះអ្នកជំងឺអេដស៍អាចទប់ទល់ប្រឆាំងនឹងជំងឺ ហើយរក្សាបានសុខភាពមាំមួន ។ ប៉ុន្តែវីរុសហ៊ីវមិនជាដាច់ឡើយ ។ វីរុសមួយចំនួនតូចនៅតែស្ថិតក្នុងរាងកាយអ្នកជំងឺជានិច្ច ។ កាលណាបុគ្គលម្នាក់កើតជំងឺអេដស៍ បុរស ឬ ស្ត្រីអាចចម្លងវីរុសនៅឱ្យអ្នកផ្សេងទៀតជានិច្ច ។

ការទទួលបានការគាំពារសុខភាពល្អ ជារឿយៗមិនងាយស្រួលឡើយសំរាប់ស្ត្រីពិការ និងចំពោះបុគ្គលផ្ទុកវីរុសហ៊ីវ/អេដស៍ វាកាន់តែពិបាកខ្លាំងថែមទៀត ។ បុគ្គលិកសុខាភិបាលអាចមិនចង់ធ្វើតេស្ត ឬ ពិនិត្យសុខភាពឱ្យពួកគេ ពីព្រោះបុគ្គលិកសុខាភិបាលគិតថា ស្ត្រីពិការមិនអាចមានការរួមរ័ក្ស, មិនអាចឆ្លងជំងឺវីរុស/អេដស៍, ឬ នឹងស្លាប់ភ្លាមកាលណាពួកគេបានឆ្លងជំងឺ ។

ស្ត្រីពិការមានបញ្ហារងគ្រោះចំពោះការឆ្លងវីរុសហ៊ីវដូចស្ត្រីឯទៀតអញ្ចឹងដែរ ប៉ុន្តែពួកគេក៏អាចរស់នៅបានយឺនយូរ និងមានសុខភាពមាំមួន កាលបើពួកគេទទួលបានការព្យាបាលត្រឹមត្រូវ ។

## ការព្យាបាលតាមវិធីប្រើថ្នាំពន្យារពេល អង់ទីរ៉េត្រូវីរ៉ាល់ តេរ៉ាពី (អាត) [AntiRetroviral Therapy (ART)]

ការព្យាបាលតាមវិធីថ្នាំពន្យារពេល**អង់ទីរ៉េត្រូវីរ៉ាល់ តេរ៉ាពី** (**អាត**/ART) មានន័យថា ថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់**ចំនួន 3 មុខបានផ្សំចូលគ្នាដើម្បីឱ្យអ្នកជំងឺលេបយ៉ាងតិចណាស់ក៏ត្រូវលេប 2 ដងក្នុងមួយថ្ងៃ ។ កាលណាបុគ្គលម្នាក់ចាប់ផ្តើមប្រើថ្នាំ**អាត** បុគ្គលនេះត្រូវតែលេបថ្នាំយ៉ាងហ្មត់ចត់ឱ្យចំម៉ោងទៀងទាត់រាល់ៗថ្ងៃ ។ ស្ត្រីម្នាក់ដែលកំពុងប្រើថ្នាំ**អាត**នឹងឡើងទំងន់ ហើយដឹងថាខ្លួនឯងមានសុខភាពមាំមួនជាងមុន ។ ប៉ុន្តែបើគាត់ឈប់ប្រើថ្នាំ**អាត** ឬ ខកខានមិនបានផឹកថ្នាំតាមកំណត់ដូសរបស់វា ឬ ផឹកវាមិនចំម៉ោងដូចសព្វដង, វីរុសក្នុងខ្លួនគាត់នឹងសើរើយ៉ាងខ្លាំងក្លាឡើងវិញ ហើយធ្វើឱ្យគាត់ឈឺចុះខ្សោយម្តងទៀត ។ ចំពោះព័តិមានអំពីថ្នាំសំរាប់ព្យាបាលវីរុស/អេដស៍សំរាប់ស្ត្រីពិការ ឬ សំរាប់ការពារកុំឱ្យវីរុសហ៊ីវរាលដាលពីម្តាយទៅទារក, ចូរអានពីទំព័រ 358 ដល់ 362 ។

ថ្វីបើថ្នាំ**អាត**ថ្លៃក៏ដោយ តំលៃថ្នាំនេះកំពុងតែចុះថោកឡើងៗ និងងាយរកបាន ឬ មានលក់ច្រើនឡើងៗនៅតាមប្រទេសជាច្រើន ។ នៅតាមសេវាកម្មរដ្ឋាភិបាល និងកម្មវិធីផ្សេងៗទៀតអាចផ្តល់ថ្នាំ**អាត**ក្នុងតំលៃទាប ឬ ផ្តល់ឱ្យមិនបង់ប្រាក់អ្វីឡើយ ។

ថ្វីបើយ៉ាងនេះក្តី នៅតាមបណ្តាសហគមន៍ជាច្រើន ថ្នាំនេះមិនមានសំរាប់ផ្តល់ឱ្យអ្នកជំងឺវីរុស/អេដស៍ស្ទើរតែទាំងអស់ ។ សិទ្ធិអំណាចនៃក្រុមហ៊ុនផលិតឱសថធំៗនៅក្នុងប្រទេសអ្នកមានៗ ជារឿយៗបានរារាំងបញ្ឈប់មិនឱ្យប្រទេសដទៃទៀតផលិតថ្នាំក្នុងប្រទេសខ្លួនផ្ទាល់ដែលមានតំលៃថោកសមរម្យ ។ ករណីនេះបដិសេធស្ត្រីរាប់លាននាក់ ចំពោះច្រកទៅរកថ្នាំដែលពួកគេត្រូវការដើម្បីព្យាបាលវីរុស/អេដស៍ ។

**ការទប់ស្កាត់ជំងឺមួយចំនួនជាមួយថ្នាំពេទ្យ**

ចំពោះអ្នកផ្ទុកវីរុស/អេដស៍ ការប្រើថ្នាំផ្សះ**កូទ្រីម៉ុកសាហ្សុល** (cotrimoxazole) ទៀងទាត់ជួយទប់ស្កាត់រោគរលាកសួត, ជំងឺរាគរូស, និងជំងឺមួយចំនួនទៀត ។ អ្នកគួរចាប់ផ្ដើមប្រើថ្នាំផ្សះនេះ បើអ្នកមានបញ្ហាជាមួយការចុះទំងន់, ជំងឺបៅ, ពងបែក, ឬ ប្រេះជុំវិញមាត់, កន្ទួលរមាស់, រើមដំរី, ពងបែកក្នុងមាត់, ឬ ផ្កាសាយញឹកញាប់ពេក ។

**ការព្យាបាល** : ចូរប្រើថ្នាំផ្សះ**កូទ្រីម៉ុកសាហ្សុល** (cotrimoxazole), (ថាមពលថ្នាំមានកំរិតខ្លាំងទ្វេរដង) ចំណុះ 960 មីលីក្រាម (mg), លេបវារៀងរាល់ថ្ងៃជាមួយទឹកឱ្យច្រើន ។ បើអាចធ្វើបាន ចូរផឹកថ្នាំនេះរៀងរាល់ថ្ងៃ ទោះបីជាអ្នកឈឺ ឬ មិនឈឺក៏ដោយ ។

***សំខាន់*** : ការប្រតិកម្មពីថ្នាំនេះ គឺកើតមានតាមធម្មតាចំពោះអ្នកជំងឺអេដស៍ ។ ចូរឈប់ផឹកថ្នាំនេះបើអ្នកឡើងកន្ទួល។លើស្បែកជាថ្មីទៀត ឬ រោគសញ្ញាផ្សេងទៀតនៃការប្រតិកម្មថ្នាំ ឬ រើអស្សុងថ្នាំ ។

***សំខាន់*** : ស្ត្រីខ្លះមានបញ្ហាច្រើនជាមួយរោគផ្សិត**យីស**នៃយោនី ក្នុងពេលពួកគេផឹកថ្នាំផ្សះទាំងឡាយ ។ ការហូបយ៉ាអួរ/ទឹកដោះគោជូរ ឬ អង្គុយត្រាំទឹកលាយយ៉ាអួរ ឬ លាយទឹកខ្មេះអាចជួយឱ្យបានធូរស្រាលច្រើន ។ ចំពោះព័ត៌មានបន្ថែមស្ដីពីរោគផ្សិត**យីស** ចូរអានពីទំព័រ 111 ដល់ 113 ។ នៅតាមប្រទេសមួយចំនួនមានការផ្ដល់ជាយោបល់ផងដែរ ដែលអ្នកជំងឺអេដស៍ត្រូវផឹកថ្នាំដើម្បីទប់ស្កាត់ជំងឺរបេង ។ ចូរទៅជួបជាមួយបុគ្គលិកសុខាភិបាលដែលមានជំនាញដើម្បីពិគ្រោះបញ្ហានេះ ។

**ការហូបចុកឱ្យបានត្រឹមត្រូវ**




ជំងឺអេដស៍ប៉ះពាល់ដល់លទ្ធភាពត្រឹមត្រូវចំពោះការរំលាយអាហាររបស់រាងកាយ និងបង្កឱ្យអ្នកជំងឺមិនសូវហូបចំណីអាហារ ទង្វើនេះធ្វើឱ្យរាងកាយអ្នកជំងឺស្គមស្គាំងផងដែរ ។ ឥទ្ធិពលនៃថ្នាំពេទ្យក៏ជាបញ្ហាអាចកើតឡើងដែរ វាបង្កបញ្ហាមាត់ និងបំពង់ក, រាគរូស, និងបង្កការលំបាករំលាយជាតិខ្លាញ់ ។

បើអ្នកផ្ទុកវីរុសហ៊ីវ វាជារឿងពិសេសណាស់ដែលអ្នកត្រូវព្យាយាមហូបម្ហូបអាហារឱ្យបានល្អ ដូច្នេះអ្នកមិនចុះទំងន់ ហើយរាងកាយនិងប្រព័ន្ធការពាររោគក្នុងខ្លួនអ្នកអាចរក្សាបានសុខភាពមាំមួន ។ ដើម្បីធ្វើបែបនេះ ចូរព្យាយាមហូបម្ហូបអាហារច្រើនយ៉ាង ឬ ឱ្យសមល្មម (អានទំព័រ 86), ផឹកទឹកស្អាត/សុទ្ធ និងផឹក**វីតាមីនចម្រុះ**ឱ្យទៀងទាត់ប្រចាំថ្ងៃ ។ បើសិនជាអាចរកបាន, អ្នកក៏អាចផឹក**វីតាមីន-អា, វីតាមីន-សេ,** និង**វីតាមីន-អ៊ី**បន្ថែមផងដែរ, វីតាមីនទាំងនេះអាចបន្ថយសមត្ថភាពវីរុសហ៊ីវកុំឱ្យលូតលាស់ក្នុងរាងកាយអ្នក ។

**ម្ហូបអាហារដែលមានវីតាមីន-អា** រួមមាន :- ការ៉ុត, ស្វាយ, ល្ពៅ, ដំឡូងជ្វា, ទឹកដោះគោ, ពងមាន់-ទា, បន្លែស្លឹកបៃតង។ (ស្លឹកខាត់ណា, ស្លឹកផ្ទី, ស្លឹកស្ពៃ, ស្លឹកម្រះ, ស្លឹកដំឡូង, ស្លឹកម្ទេស, សាឡាត់) ។ល។

**ម្ហូបអាហារដែលមានវីតាមីន-សេ** រួមមាន :- ម្ទេសប្លោកក្រហមនិងបៃតង, បន្លែស្លឹកបៃតងចាស់ (ស្លឹកខាត់ណា, ស្លឹកថ្មី, ស្លឹកជំឡូងជ្វា, ស្លឹមម្រុំ, ស្លឹកថ្មី, ស្លឹកម្រះ, សាឡាត់, និងស្លឹកស្ពៃ) និងក្រូចពោធិ៍សាត់, ផ្លែឈើដែលមានពណ៌លឿងនិងក្រហម ។

**ម្ហូបអាហារដែលមានវីតាមីន-អ៊ី** រួមមាន :- ពងមាន់-ទា, ប្រេងឆាចំរាញ់ពីគ្រាប់ធញ្ញជាតិ (អាល់មិន, ពោត, សណ្តែកដី, ត្នោត, ឈូករត្ន័ និង អូលីវ) ។

បើអ្នកបាត់បង់ការឃ្លានចំណីអាហារ អ្នកប្រហែលជារកឃើញថា ការហូបម្ហូបអាហារឱ្យច្រើននៅពេលព្រឹកអាចមានប្រយោជន៍សំរាប់អ្នក ។ ឬ អ្នកប្រហែលជាចង់ហូបម្ហូបអាហារតិច១ពី 6 ទៅ 8 ដងក្នុងរយៈពេលថ្ងៃ ។ ចូរផឹកទឹកត្រជាក់ជាមួយម្ហូបអាហារ ទឹកជួយបង្កឱ្យអ្នកលេបអាហារបានងាយស្រួលច្រើន ។

## ការរស់នៅប្រកបភាពវិជ្ជមានជាមួយវីរុស/អេដស៍




អ្នកនឹងកាន់តែមានសុខភាពមាំមួនឡើង បើអ្នកអាច :-

- ផឹកនិងរៀបចំម្ហូបអាហារជាមួយទឹកបរិសុទ្ធដែលមានសុវត្ថិភាពមួយមុខគត់ ។
- ចូរចៀសវាងហូបបន្លែឆៅ-រាងកាយអ្នកមានការលំបាករំលាយបន្លែឆៅ និងវាអាចមានមេរោគ ។
- ចូរផឹកទឹកឱ្យបានច្រើន ហើយសំគាល់មើលការខ្សោះជាតិទឹកក្នុងខ្លួន ។
- ចូរសម្រាកកាលណាអ្នកមានអារម្មណ៍អស់កំលាំង ហើយដេកឱ្យបាន 8 ម៉ោងយ៉ាងតិច ។
- ចំណាយពេលសំណេះសំណាលជាមួយមិត្តភក្តិ និងក្រុមគ្រួសារ ។
- ចូរធ្វើអ្វី១ដែលអ្នករីករាយនឹងធ្វើ ។ ការមានអារម្មណ៍ល្អជាចំណែកនៃសុខុមាលភាពមាំមួន ។
- ចូរព្យាយាមកុំព្រួយចិត្តច្រើនពេក ។ ការតឹងតែងចិត្តអាចបង្កទុក្ខទោសដល់ប្រព័ន្ធការពាររោគក្នុងខ្លួនអ្នក ។
- ចូរធ្វើកិច្ចការប្រចាំថ្ងៃរបស់អ្នក ដើម្បីរក្សាខ្លួនអ្នកឱ្យជាប់រវល់យ៉ាងសកម្ម ។
- ចូរហាត់ប្រាណឱ្យបានច្រើនតាមដែលអាចធ្វើបាន (ចូរអានពីទំព័រ 89 ដល់ 95) ។
- ចូរចៀសវាងជក់បារី ឬ ប្រើថ្នាំជក់, ហាមផឹកគ្រឿងស្រវឹង និងគ្រឿងញៀនទាំងឡាយ ។
- ចូរទប់ស្កាត់ជំងឺឆ្លងដោយការលាងសំអាតឱ្យបានញឹកញាប់ ។
- ចូរអនុវត្តសុវត្ថិភាពរួមរ័ក្សដើម្បីទប់ស្កាត់ជំងឺឆ្លងថ្មី១ និងការមានផ្ទៃពោះមិនបានគ្រោងទុក ដែលវាអាចធ្វើឱ្យប្រព័ន្ធការពាររោគក្នុងខ្លួនចុះខ្សោយ (ចូរអានទំព័រ 180) ។
- ចូរទៅរកការគាំពារផ្នែកវេជ្ជសាស្ត្រឱ្យទាន់ពេល ។ ជំងឺឆ្លងនីមួយ១អាចធ្វើឱ្យប្រព័ន្ធការពាររោគក្នុងខ្លួនកាន់តែខ្សោយខ្លាំង ។
- ចូរលេបថ្នាំផ្សះ**កូទ្រីម៉ុកសាហ្សុល** ដើម្បីការពារកុំឱ្យមានជំងឺរាគរូស (ចូរអានទំព័រ 339) ។
- ចូរដេកលើគ្រែនិងដាក់មុងឱ្យត្រឹមត្រូវ បើអ្នករស់នៅតំបន់ដែលតែងកើតមានជំងឺគ្រុនចាញ់ ។



## ការរាប់អានកិត្តិយស និង មេរោគហ៊ីវ/អេដស៍

នៅតាមសហគមន៍មួយចំនួន មនុស្សដែលផ្ទុកវីរុសហ៊ីវ ឬ កើតជំងឺអេដស៍ត្រូវបានធ្វើឱ្យមានអារម្មណ៍អាម៉ាស់។ មនុស្សម្នាក្នុងសហគមន៍មិនរាប់រករាក់ទាក់ជាមួយពួកគេឡើយ ហើយមនុស្សម្នាក៏មានគំនិតផងដែរថា ក្រុមគ្រួសារនៃបុគ្គលដែលផ្ទុកវីរុសហ៊ីវ/អេដស៍បានធ្វើឱ្យអាប់អោនកិត្តិយសរបស់សហគមន៍។ មនុស្សផ្ទុកវីរុសហ៊ីវ ឬ កើតជំងឺអេដស៍រាប់ពាន់នាក់បានលាក់បាំងរឿងរ៉ាវរបស់ខ្លួន។ ពួកគេភ័យខ្លាចមិត្តភក្តិ, ក្រុមគ្រួសារ, និងញាតិជិតខាងលែងរាប់អាន ថ្វីបើវីរុសហ៊ីវ/អេដស៍មិនឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈការនិយាយស្តីដែលជាទំនាក់ទំនងធម្មតាក៏ដោយ។

មនុស្សកើតអេដស៍ជាច្រើននាក់និងក្រុមគ្រួសារមិនស្នើសុំការជួយយកអាសារពីសហគមន៍របស់ខ្លួនឡើយ ដោយសារពួកគេមានអារម្មណ៍អាម៉ាស់ និងការមាក់ងាយពីសហគមន៍មកលើពួកគេ។ រឿងនេះអាចធ្វើឱ្យពិបាកថែមទៀតសំរាប់បុគ្គលកើតអេដស៍ក្នុងការទទួលបានការជួយនិងការព្យាបាលដែលគាត់ត្រូវការ ថ្វីបើមានថ្នាំពេទ្យដែលជួយពន្យារពេលឱ្យមនុស្សកើតអេដស៍រស់នៅបានយូរនិងមានសុខភាពមាំមួនឡើងវិញក៏ដោយ។

## ការទប់ស្កាត់ជំងឺឆ្លងនៅផ្ទះ

មនុស្សជាច្រើនតែងគិតថា វីរុសហ៊ីវឆ្លងយ៉ាងងាយស្រួល។ រឿងនេះមិនពិតឡើយ។ បើអ្នកធ្វើតាមគោលការណ៍ណែនាំទាំងនេះ នោះវាគ្មានគ្រោះថ្នាក់នៃការរាលដាលវីរុសហ៊ីវ ឬ ឆ្លងជំងឺថ្លើមពីអ្នកផ្ទុកមេរោគដល់មនុស្សទាំងឡាយដែលនៅជុំវិញគាត់ ឬ អ្នកក៏មិនឆ្លងវីរុសហ៊ីវ ឬ ជំងឺថ្លើមឡើយ :-



- ហាមប្រើវត្ថុរួមគ្នាដែលប៉ះពាល់នឹងឈាម។ រួមទាំង ឡាម, ម្ជុល, ឧបករណ៍មុតទាំងឡាយដែលអាចកាត់ស្បែកជាច់ និងច្រាស់ដុសធ្មេញ។ បើអ្នកត្រូវតែប្រើវត្ថុនោះរួមគ្នា ដាំទឹកស្ងោរវាចំនួន 20 នាទីជាមុនសិន ទើបយកវាទៅប្រើ។
- ចូរបិតដំបៅទាំងអស់ជាមួយបង់បិតដំបៅ ឬ កំណាត់ស្អាត។ បុគ្គលដែលមាន ឬ គ្មានវីរុសហ៊ីវ ឬ ជំងឺថ្លើមក៏គួរតែធ្វើបែបនេះដែរ។
- បង់/ស្បៃរុំដំបៅគគ្រិចដែលមិនអាចបោកគក់បាន ត្រូវតែដុត ឬ កប់ចោល។
- ចូរចៀសវាងប៉ះពាល់ទឹករងៃដោយដៃទទេ។ ប្រើចំរៀកប្លាស្ទិក ឬ ក្រដាស, ស្រោមដៃពេទ្យ ឬ ស្លឹកឈើធំៗទ្រាប់ដៃពេលអ្នកចាប់កាន់វត្ថុគគ្រិចៗដូចជា បង់/ស្បៃរុំដំបៅ, កំណាត់, ឈាម, ឬ លាមក។
- ចូរលាងដៃអ្នកជាមួយទឹកនិងសាប៊ូ ក្រោយពេលផ្លាស់ប្តូរកន្ទេល/កំរាលពូល, ភួយ, និងខោអាវប្រឡាក់។
- ចូររក្សាកន្ទេល/កំរាលពូល, ភួយ, និងខោអាវឱ្យស្អាតជានិច្ច។ ដើម្បីបោកគក់កន្ទេល/កំរាលពូល, ភួយ, និងខោអាវប្រឡាក់ ចូរធ្វើដូចខាងក្រោម :-
  - ទុកដាក់វត្ថុរបស់អ្នកជំងឺ ដែលប្រឡាក់ជាច់ដោយឡែកពីវត្ថុប្រចាំផ្ទះទាំងឡាយ។
  - ចូរកាន់ជាយវត្ថុទាំងនោះត្រង់កន្លែងដែលមិនគគ្រិច ហើយជះទឹកលាងសំអាតកន្លែងដែលទឹករងៃនៃដំបៅជាមប្រឡាក់។
  - ចូរបោកគក់កន្ទេល/កំរាលពូល, ភួយ, និងខោអាវប្រឡាក់ក្នុងទឹកមានសាប៊ូច្រើន ហើយព្យួរហាលឱ្យស្ងួត-បើអាចចូរហាលក្រោមកំដៅថ្ងៃ ហើយអ៊ុតនិងបត់តាមធម្មតា។



- ពេលបោកគក់កន្ទេល/កំរាលពូល, ភួយ, និងខោអាវប្រឡាក់ វាគឺជាការមានប្រយោជន៍ ប៉ុន្តែមិនចាំបាច់ទេក្នុងការពាក់ស្រោមដៃ ឬ ប្រើស្បោងប្លាស្ទិករុំដៃរបស់អ្នក។

## វិធីផ្សេងៗទៀតដើម្បីទប់ស្កាត់វីរុសហ៊ីវ

- ចូរព្យាបាលជំងឺកាមរោគឱ្យទាន់ពេល ។ ការមានជំងឺកាមរោគមួយក្នុងខ្លួន វាអាចធ្វើឱ្យងាយផ្ទុកវីរុសហ៊ីវ ឬ ជំងឺកាមរោគផ្សេងៗទៀត ។
- កុំចាក់ថ្នាំ ដរាបណាអ្នកដឹងច្បាស់ថាឧបករណ៍សំរាប់ចាក់ថ្នាំទាំងអស់បានសំលាប់មេរោគជាមុនសិន ។ បុគ្គលិកសុខាភិបាល **ជាច់ខាត** កុំយកម្ជុល ឬ ស៊ីរ៉ាំងដែលប្រើហើយមកប្រើឡើងវិញដោយគ្មានការសំលាប់មេរោគជាមុន ។
- ហាមប្រើម្ជុល ឬ ស៊ីរ៉ាំងជាមួយបុគ្គលផ្សេងទៀត ដរាបណាវាបានសំលាប់មេរោគ ឬ ស្ងោរចំនួន 20 នាទីជាមុនសិន ។
- ធ្វើយ៉ាងណាយកឧបករណ៍ដែលប្រើសំរាប់វះកាត់ស្បែកចុងលិង្គ, ចោះត្រចៀក, ចាក់ម្ជុលវិទ្យាសាស្ត្រ, និងការអនុវត្តក្បួនពេទ្យបុរាណដូចជាព្យាបាលសំលាកស្បែកទៅស្ងោរសំលាប់មេរោគចំនួន 20 នាទីជាមុនសិន ។
- ចូរកាន់កាប់អង្គធាតុរាងកាយដូចជា ឈាម, កំអួត, លាមក និងទឹកនោមដោយប្រយ័ត្នប្រយែង ។
- ឈាមទាំងអស់គួរត្រូវតែធ្វើតេស្តដើម្បីដឹងច្បាស់ថា វាគ្មានផ្ទុកវីរុសហ៊ីវ ឬ ជំងឺថ្លើម ។ ថ្វីបើវាបានធ្វើតេស្តហើយក៏ដោយ ចូរចៀសវាងការបញ្ចូលឈាម លើកលែងតែមានករណីសង្គ្រោះបន្ទាន់ដែលកំពុងគំរាមគំហែងអាយុជីវិត ។



## ការរួមភេទដោយសុវត្ថិភាព

ស្ទើរតែគ្រប់ពេលទាំងអស់ វីរុសហ៊ីវនិងជំងឺកាមរោគដទៃទៀត គឺបានឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតក្នុងពេលកំពុងរួមភេទ ។ អ្នកអាចការពារខ្លួនពីជំងឺកាមរោគជាមួយព័ត៌មានអំពីសុវត្ថិភាពរួមភេទ, គោរព, មានច្រករកបានស្រោមអនាម័យមកប្រើប្រាស់, ការប្រាស្រ័យទាក់ទងនិងការនិយាយជាមួយដៃគូ/ប្តីរបស់អ្នក ។




ប៉ុន្តែវាអាចជាការពិបាកសំរាប់ស្ត្រីគ្រប់រូប ចំពោះការការពារខ្លួនពីជំងឺឆ្លងតាមការរួមភេទ ពេលគាត់មិនបានគ្រោងទុក ឬ អនុញ្ញាតក្នុងការសំរេចចិត្តអំពីរឿងរួមភេទ ។ អ្នកប្រហែលជាខ្លាច ឬ ក៏ខ្មាសក្នុងការស្នើសុំឱ្យបុរសប្រើស្រោមអនាម័យ ឬ អ្នកត្រូវតែរួមភេទពេលដៃគូ/ប្តីរបស់អ្នកបញ្ជា ។ ហើយអ្នកប្រហែលជាមិនបានដឹងថាតើដៃគូ/ប្តីរបស់អ្នកបានរួមភេទនឹងមនុស្សផ្សេងទៀតដែរឬយ៉ាងណា ។ ស្ត្រីរាល់រូបត្រូវការដឹងពីរបៀបដែលគាត់អាចធ្វើដើម្បីឱ្យការរួមភេទមានសុវត្ថិភាព ។

## វិធីរួមភេទដោយសុវត្ថិភាព

ការអនុវត្តសុវត្ថិភាពរួមភេទមានន័យថាការប្រើរបាំងរារាំង (ដូចជាស្រោមអនាម័យ) ដើម្បីទប់ស្កាត់មេរោគមិនឱ្យឆ្លងរវាងអ្នកនិងដៃគូ/ប្តី ឬ ការរួមភេទតាមវិធីដែលកាត់បន្ថយជំងឺមិនឱ្យឆ្លងដល់គ្នា។ ការរួមភេទជាមួយលិង្គនិងរន្ធយោនី (ការរួមសង្វាស) គឺជាវិធីកើតឡើងស្ទើរតែទូទៅដែលបុរសនិងស្ត្រីធ្វើការរួមភេទ។ ប៉ុន្តែប្តីប្រពន្ធអាចផ្តល់និងទទួលការរំភើបរីករាយនឹងការរួមភេទដោយការប្រើប្រភេទផ្សេងៗជាច្រើនតាមរយៈការនិយាយនិងការស្ទាបអង្អែល។ បើដៃគូ/ប្តីមិនចង់ប្រើស្រោមអនាម័យ អ្នកអាចព្យាយាមអនុវត្តវិធីរួមភេទតាមបែបផ្សេងៗដែលមានសុវត្ថិភាព។ ការអនុវត្តទាំងនេះអាចធ្វើឱ្យដៃគូ/ប្តីស្រណុកស្រួល-ហើយមានសុវត្ថិភាពច្រើនសំរាប់អ្នក។

### មានសុវត្ថិភាពកាន់តែច្រើន

- ចៀសវាងការរួមភេទទាំងស្រុង។ បើអ្នកមិនរួមភេទ អ្នកនឹងមិនមានឆ្លងជំងឺកាមរោគឡើយ។ ស្ត្រីខ្លះអាចរកឃើញថា វិធីនេះគឺជាជំរើសល្អបំផុត ជាពិសេសពេលពួកគេនៅវ័យក្មេង។ ទោះជាយ៉ាងណាក៏ដោយ សំរាប់ស្ត្រីស្ទើរតែទាំងអស់ ជំរើសនេះ គឺមិនអាចធ្វើបាន ឬ មិនមែនជាក្តីប៉ងប្រាថ្នា។



- ការរួមភេទជាមួយបុគ្គលតែម្នាក់គត់ ដែលអ្នកដឹងច្បាស់ថាគាត់បានរួមភេទជាមួយអ្នកម្នាក់គត់ ហើយពេល (តាមរយៈការធ្វើតេស្ត) អ្នកដឹងច្បាស់ថា អ្នកទាំងពីរមិនបានឆ្លងជំងឺអ្វីមួយពីដៃគូមុនៗឡើយ។
- ការរួមភេទដោយការស្ទាបអង្អែលឱ្យគ្នាទៅវិញទៅមក និងការស្ទាបអង្អែលប្រដាប់ភេទអ្នកដោយប្រើដៃរបស់អ្នក (ការធ្វើឱ្យកើនសំរើបស្រណុកស្រួលទាំងសងខាង)។
- ប្រើស្រោមអនាម័យនៅពេលកំពុងរួមភេទដោយប្រើមាត់។ របាំងនៃកៅស៊ូ ឬ ប្លាស្ទិកជួយទប់ស្កាត់ជំងឺរើមនិងប្រមេះមិនឱ្យកើតក្នុងបំពង់ក។ វាក៏ការពារប្រឆាំងគ្រោះថ្នាក់នៃជំងឺឆ្លងជាមួយវីរុសហ៊ីវតាមរយៈការដាច់រលាត់តិចតួចក្នុងមាត់។

### មានសុវត្ថិភាព

- ចូរប្រើស្រោមអនាម័យផលិតពីជ័រកៅស៊ូជានិច្ច-ទាំងបុរស ឬ ស្ត្រីក៏ដោយ-នៅពេលកំពុងរួមភេទជាមួយលិង្គនិងយោនី ឬ លិង្គនិងរន្ធគូទ។
- ការរួមភេទតាមវិធីដែលចៀសវាងកុំឱ្យអង្គធាតុពីរាងកាយរបស់ដៃគូ/ប្តីចូលក្នុងរន្ធយោនី ឬ រន្ធគូទរបស់អ្នក។
- ការរួមភេទដោយប្រើមាត់របស់អ្នក គឺមិនសូវឆ្លងវីរុសហ៊ីវឡើយ។ បើអ្នកធ្វើឱ្យទឹកកាមចូលមាត់ ចូរស្តោះវាចេញ។

**ប្រភេទរួមរ័ក្សមួយចំនួនរវាង បុរសនិងស្ត្រី គឺមានសុវត្ថិភាពជាង ប្រភេទរួមរ័ក្សមួយចំនួនទៀត។**


ការថើបមានសុវត្ថិភាព


ការស្ទាបអង្អែលមានសុវត្ថិភាព


ការរួមរ័ក្សតាមមាត់ដោយ មិនប្រើស្រោមអនាម័យ គឺមិនសូវមានសុវត្ថិភាព។


ការរួមរ័ក្សនឹងរន្ធយោនីគឺមានគ្រោះថ្នាក់ច្រើន ប៉ុន្តែមានសុវត្ថិភាពច្រើន ដោយប្រើស្រោមអនាម័យ។


ការរួមរ័ក្សនឹងរន្ធគូទគឺមានគ្រោះថ្នាក់ច្រើន ប៉ុន្តែមានសុវត្ថិភាពច្រើន ដោយប្រើស្រោមអនាម័យ។

### វិធីផ្សេងទៀតដើម្បីរួមរ័ក្សដោយសុវត្ថិភាពជាមួយបុរស

- ការឱ្យបុរសយកលិង្គចេញពីរន្ធយោនីមុនគាត់បញ្ចេញទឹកកាម ។ កាលណាទឹកកាមចូលក្នុងខ្លួនអ្នកតិច នោះអ្នកនឹងមានឱកាសតិចតួចក្នុងការឆ្លងវីរុសហ៊ីវពីបុរស ។
- ចូរចៀសវាងការរួមរ័ក្សដែលស្ងួត ។ កាលណារន្ធយោនី (ឬ រន្ធគូទ) ស្ងួត ស្បែកងាយដាច់រហែកណាស់ ហើយករណីនេះបង្កើនឱកាសនៃជំងឺឆ្លង ។ ចូរប្រើទឹកមាត់ ឬ ក្រែមសំលាប់មេជីវិត ឬ ក្រែម**ខេ-វ៉ាយ**ដើម្បីលាបរន្ធយោនីឱ្យរអិល ។ បើអ្នកប្រើស្រោមអនាម័យ ហាមប្រើប្រេង, ឡេលាបស្បែក, ឬ ក្រមួនប្រេងកាត (វ៉ាស៊ីលីន) អង្គធាតុទាំងនេះធ្វើឱ្យស្រោមអនាម័យរហែក ។

### ការរួមរ័ក្ស និង ឈាមរដូវ

នៅអំឡុងពេលអ្នកមានឈាមរដូវ ជារឿងល្អបំផុតកុំរួមរ័ក្សជាមួយរន្ធយោនី ដរាបណាអ្នកដឹងច្បាស់ថា អ្នកនិងដៃគូ/ប្តីគ្មានផ្ទុកវីរុសហ៊ីវ/អេដស៍ ឬ ជំងឺកាមរោគផ្សេងៗ ។ បើអ្នកផ្ទុកវីរុសហ៊ីវ, វីរុសនឹងបង្កប់ខ្លួនវាក្នុងកន្លែងសំងាត់នៃរន្ធយោនីនិងឈាមរបស់អ្នក ។ ករណីនេះនឹងបង្កើនឱកាសចម្លងវីរុសនេះដល់ដៃគូ/ប្តីអ្នក ។ បើដៃគូ/ប្តីអ្នកផ្ទុកវីរុសហ៊ីវ ហើយអ្នកគ្មានវីរុសហ៊ីវ នោះអ្នកនឹងកើនឱកាសឆ្លងវីរុសហ៊ីវ បើអ្នករួមភេទក្នុងពេលអ្នកមានឈាមរដូវ ។ ការប្រើស្រោមអនាម័យនឹងកាត់បន្ថយគ្រោះថ្នាក់បានច្រើន ។

## ធ្វើការសំរាប់ការផ្លាស់ប្តូរដ៏ល្អប្រពៃ

ជំងឺកាមរោគ និងវីរុសហ៊ីវ/អេដស៍ គឺជាបញ្ហាសុខភាពសំរាប់សហគមន៍ទាំងមូល រួមទាំងស្ត្រីពិការផងដែរ ។ ជួនកាល ក្រុមពិការភាពគិតថា សុខភាពផ្លូវភេទមិនមែនជារឿងដែលពួកគេត្រូវព្រួយបារម្ភឡើយ ។ ប៉ុន្តែការអប់រំសុខភាពផ្លូវភេទអាចជួយសង្គ្រោះជីវិតមនុស្សបាន ។

ព័ត៌មានស្តីពីការអប់រំសុខភាពផ្លូវភេទ និងអំពីវិធីទប់ស្កាត់ជំងឺកាមរោគត្រូវតែមានបំរើដល់មនុស្សគ្រប់រូប រួមទាំងស្ត្រីពិការផងដែរ ។ ឧទាហរណ៍អំពីព័ត៌មានលើការទប់ស្កាត់វីរុសហ៊ីវ/អេដស៍ ជារឿយៗត្រូវបានផ្សាយតាមវិទ្យុ ឬ បោះពុម្ពជាសៀវភៅស្តើងៗ គួរតែមានចែកចាយ ហើយមានជាភាសាសញ្ញាសំរាប់មនុស្សថ្លង់ និងភាសាប្រៃយ៍សំរាប់ជនពិការភ្នែក ។

### អ្វីៗដែលស្ត្រីពិការអាចធ្វើបាន




- ជួបជាមួយអ្នកថែទាំនិងក្រុមគ្រួសាររបស់ស្ត្រីពិការដើម្បីរៀបរាប់ពន្យល់ពីសារៈសំខាន់សំរាប់បុគ្គលម្នាក់ៗក្នុងការទទួលព័ត៌មានល្អៗអំពីសុខភាពផ្លូវភេទ ។
- ធ្វើការជាមួយបុគ្គលិកសុខាភិបាល និងក្រុមឯទៀតៗដើម្បីធ្វើឱ្យប្រាកដថា សេវាបំរើផ្នែកវីរុសហ៊ីវ/អេដស៍ និងសុខភាពផ្លូវភេទបានទៅដល់ជនពិការទូទៅ ។
- បើនរណាម្នាក់ប្រព្រឹត្តិមកលើអ្នកតាមបែបកេងប្រវ័ញ្ចក្នុងរឿងផ្លូវភេទ ចូរប្រាប់រឿងនេះដល់បុគ្គលណាម្នាក់ដែលអ្នកទុកចិត្ត ដូចជាសមាជិកគ្រួសារ, ញាតិជិតខាង, ឬ បុគ្គលិកសុខាភិបាល ។

### អ្វីៗដែលក្រុមគ្រួសារនិងអ្នកថែទាំអាចធ្វើបាន




- ចូរធ្វើឱ្យប្រាកដថា ស្ត្រីពិការមានព័ត៌មានអំពីសុខភាពផ្លូវភេទ និងវិធីទប់ស្កាត់វីរុសហ៊ីវ/អេដស៍ ព្រមទាំងជំងឺកាមរោគ ។ ចូរផ្តល់ព័ត៌មានតាមរបៀបគារពសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គល ។
- ចូរជួយយកអាសារឪពុកម្តាយនៃកុមារពិការឯទៀត ឱ្យគាត់បានយល់ថា កាលណាកូនដែលពិការធំពេញវ័យ កូននោះនឹងមានទំនាក់ទំនងខាងផ្លូវភេទ ដូចកូនមិនពិការអញ្ចឹងដែរ ។

### អ្វីៗដែលសហគមន៍អាចធ្វើបាន

វាគឺជារឿងសំខាន់សំរាប់មនុស្សគ្រប់រូបក្នុងសហគមន៍ដើម្បីយល់ដឹងពីវិធីដែលវីរុសហ៊ីវ/អេដស៍ និងជំងឺកាមរោគបានរាលដាល និងវិធីទប់ស្កាត់វា ។ ជាមួយព័ត៌មាននេះ មនុស្សម្នានឹងស្វែងយល់ថា ជំងឺឆ្លងទាំងនេះអាចកើតឡើងចំពោះមនុស្សទាំងឡាយដោយមិនរើសមុខ ហើយពួកគេអាចធ្វើសកម្មភាពទប់ស្កាត់វា ។ ហើយចំណេះដឹងទាំងនេះអាចជួយឱ្យមនុស្សយល់ដឹងបានច្បាស់ថា ស្ត្រីពិការមានតម្រូវការផ្នែកសេវាគាំពារសុខភាព ដូចមនុស្សគ្រប់គ្នាទូទៅក្នុងសហគមន៍ដែរ ។

វាគឺជារឿងសំខាន់ដើម្បីតតាំងប្រឆាំងនឹងស្ថានភាពដែលបណ្តាលឱ្យជំងឺរាតត្បាត ហើយកុំប្រឆាំងនឹងអ្នកជំងឺផ្ទាល់ ។ វិធីដែលអាចទប់ស្កាត់វីរុសហ៊ីវ/អេដស៍ និងជំងឺកាមរោគបានល្អបំផុត គឺតាមរយៈការតស៊ូមតិដើម្បីធ្វើឱ្យការប្រាស្រ័យទាក់ទងផ្នែកសង្គម និងស្ថានភាពសេដ្ឋកិច្ចបានរីកចំរើនឡើង ធ្វើដូច្នេះស្ត្រីទូទៅ រួមទាំងស្ត្រីពិការផងដែរ មានឥទ្ធិពលច្រើនឡើងក្នុងការសំរេចចិត្តបែបនេះ ក្រុមគ្រួសារមិនចាំបាច់រស់នៅបែកគ្នាដើម្បីរកការងារធ្វើ ហើយមនុស្សមិនត្រូវការលក់ដូរខ្លួនប្រាណសំរាប់ការរួមរ័ក្សផងដែរ ។

- ចូរធ្វើឱ្យប្រាកដថាឱ្យមនុស្សគ្រប់គ្នា រួមទាំងស្ត្រីពិការផងដែរមានច្រកទៅរកព័ត៌មាន និងសេវាផ្នែកសុខភាពផ្លូវភេទ រួមមានស្រោមអនាម័យ, ទប់ស្កាត់វីរុសហ៊ីវ និងជំងឺកាមរោគផ្សេងទៀតមិនឱ្យឆ្លងដល់មនុស្សម្នាក្នុងសហគមន៍ ។
- ចូរធ្វើយ៉ាងណាឱ្យមានថ្នាំពេទ្យ, ទឹកស្អាត, និងម្ហូបអាហារមានជីវជាតិសំរាប់មនុស្សដែលកំពុងរស់នៅជាមួយវីរុសហ៊ីវ/អេដស៍ ។
- ចូរធ្វើការអប់រំមនុស្សក្នុងសហគមន៍របស់អ្នក ដើម្បីការពារក្មេងស្រីនិងស្ត្រីពិការពីមនុស្សដែលកេងយកចំណេញខាងផ្លូវភេទ និងឱ្យជនឆ្លៀតឱកាសទាំងឡាយបានយល់ច្បាស់ថា ការរួមរ័ក្សជាមួយក្មេងស្រីពិការ/ស្ត្រីពិការ មិនធ្វើឱ្យជំងឺអេដស៍ជាសះស្បើយឡើយ ។

**ជូនចំពោះបុគ្គលិកសុខាភិបាល**



ចូរដាក់បញ្ចូលស្ត្រីពិការក្នុងវគ្គសិក្សាស្តីការអប់រំសុខភាពទាំងឡាយដែលអ្នកនឹងធ្វើការបណ្តុះបណ្តាល ហើយសង្កេតរកមើលឱកាសដើម្បីចែករំលែកព័ត៌មានជាមួយក្រុមស្ត្រីពិការដែលធ្លាប់បានធ្វើការប្រជុំរួចមកហើយ ។ ចូរគោរពសិទ្ធិផ្ទាល់ខ្លួនរបស់ស្ត្រីពិការ ។

**ហាម**និយាយអំពីបញ្ហារបស់ស្ត្រីជាមួយមនុស្សផ្សេងៗទៀត ទោះបីជាមនុស្សទាំងនោះជាក្រុមគ្រួសាររបស់នាងក៏ដោយ ដរាបណាស្ត្រីដែលជាសាមីខ្លួនផ្តល់ការអនុញ្ញាតឱ្យអ្នកជាមុនសិន ។

- ចូរនិយាយពន្យល់ពីរបៀបដែលជំងឺកាមរោគ និងវីរុសហ៊ីវ/អេដស៍ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត និងវិធីដើម្បីការពាររោគឆ្លងទាំងនេះ ។ ចូរបង្ហាញរបៀបប្រើស្រោមអនាម័យសំរាប់បុរស និងរបៀបប្រើស្រោមអនាម័យសំរាប់ស្ត្រី ( ចូរអានពីទំព័រ 190 ដល់ 191) ។
- ចូរស្វែងយល់អំពីបញ្ហាដែលអាចកើតឡើងចំពោះស្ត្រីពិការមួយចំនួន នៅក្នុងការលេបថ្នាំណាមួយជាក់លាក់ដើម្បីព្យាបាលជំងឺកាមរោគ ។
- ចូរសំគាល់មើលរោគសញ្ញានៃការរំលោភបំពានខាងផ្លូវភេទ នៅពេលអ្នកជួបស្ត្រីដើម្បីពិនិត្យបញ្ហាសុខភាពអ្វីក៏ដោយ ។
- ចូរធ្វើយ៉ាងណាឱ្យស្ត្រីពិការមានច្រកទៅរកការពិគ្រោះបញ្ហានិងការធ្វើតេស្តវីរុសហ៊ីវ ។

បុគ្គលិកសុខាភិបាលអាចផ្តល់ការណែនាំដល់ឪពុកម្តាយរបស់កុមារពិការឱ្យបានដឹងច្បាស់ថា កុមារដែលបានសិក្សាស្វែងយល់អំពីជំងឺកាមរោគ រួមទាំងវីរុសហ៊ីវ/អេដស៍ផងដែរនោះ នឹងចេះធ្វើការពិចារណាជ្រើសរើស ហើយចេះគិតគូរពីសុវត្ថិភាពរបស់ខ្លួននៅពេលអនាគត គឺពេលពួកគេធំពេញវ័យ ហើយចាប់ផ្តើមមានការរួមរ័ក្ស ។